ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី ឃុំថ្មស

## ឆ្នាំ ២០០៩-២០២២

## ស្រុក បូទុមសាគរ ខេត្ត កោះកុង



រៀបចំដោយៈ គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

គាំទ្រដោយៈ ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិការ


**អារម្ភកថា** ........ 1

**សេចក្តីផ្តើម** ........ 2

**ប្រវត្តិនៃឃុំថ្មស** ........ 3

**ជំពូក ១** ........ 4

**១.១. ស្ថានភាពទូទៅ** ........ 4

១.១.១. ទីតាំងដីរដ្ឋបាល ........ 5

១.១.២. ប្រជាសាស្រ្ត ........ 5

១.១.៣. ភាពគ្មានដីធ្លី ........ 5

១.១.៤. ស្ថានភាពសេដ្ឋកិច្ច ........ 6

១.១.៥. ស្ថានភាពអប់រំ និងសិក្សាធិការ ........ 7

១.១.៦. ស្ថានភាពសុខាភិបាល ........ 8

១.១.៦.១. ផ្នែកសុខាភិបាល ........ 8

១.១.៦.២. ការផ្គត់ផ្គង់ទឹកស្អាត ........ 8

**១.២. ស្ថានភាពភូមិសាស្រ្ត** ........ 9

១.២.១ ទីតាំងភូមិសាស្រ្ត ........ 9

១.២.២. រយៈកំពស់ ........ 9

១.២.៣. អាកាសធាតុ : ........ 10

១.២.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ដឹកជញ្ជូន ........ 11

**១.៣. ស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន** ........ 12

១.៣.១. ស្ថានភាពនៃការប្រើប្រាស់ដី ........ 12

១.៣.២. ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ........ 13

១.៣.៣. ផលិតកម្មកសិកម្ម ........ 14

១.៣.៤. ធនធានធម្មជាតិ ........ 17

១.៣.៤.១. ធនធានព្រៃឈើ ........ 17

១.៣.៤.២. ធនធានជលផល ........ 18

**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ........ 18
១.៤.១. ទីផ្សារ និងតំលៃកសិផល អនុផលព្រៃឈើ និងផលនេសាទ ........ 18
១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល ........ 19
១.៤.៣. ឱកាស-ឧបសគ្គ ........ 20
**ជំពូក ២ : ការវិភាគពីតំរូវការសំរាប់អនាគត ឧបសគ្គ និងសក្តានុពល** ........ 20
**២.១. តំបន់សើប** ........ 20
**២.២. ការប្រឈម/ឧបសគ្គ** ........ 20
**២.៣. កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តឃុំថ្មស** ........ 21
**២.៤. តំរូវការសំរាប់អនាគត** ........ 22
២.៤.១ ប្រជាសាស្រ្ត ........ 22
២.៤.១.១. អត្រាកំណើន ........ 22
២.៤.១.២. ការធ្វើចំណោលប្រជាសាស្រ្ត ........ 23
២.៤.២. តំរូវការសំរាប់លំនៅដ្ឋាន ........ 24
២.៤.៣. តំរូវការដីកសិកម្ម ........ 24
២.៤.៤. តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ........ 26
២.៤.៥. តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ........ 26
២.៤.៥.១. តំរូវការដីសាលារៀន ........ 27
២.៤.៥.២. សេវាកម្មសុខភាព និង ការផ្គត់ផ្គង់ទឹកស្អាត ........ 28
២.៤.៥.៣. ផ្នែកវប្បធម៌ និងសាសនា ........ 29
២.៤.៥.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ........ 30
**ជំពូក ៣ : ផែនការប្រើប្រាស់ដីអនាគត** ........ 31
**៣.១. ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ........ 31
៣.១.១. ស្ថានភាពដីទូទៅ និងសក្តានុពល ........ 31
៣.១.២. តំរូវការដីតាមប្រភេទ ........ 32
**៣.២. ការបែងចែកដីតាមតំរូវការប្រើប្រាស់** ........ 33
៣.២.១. ការវិភាគអន្តរអំពើ ........ 33

៣.២.២. ផែនទីប្រើប្រាស់ដីពេលអនាគត....................................................................................................34

៣.២.៣. ការបរិយាយការប្រើប្រាស់តាមក្បាលដី....................................................................................35

៣.២.៣.១. ដីលំនៅដ្ឋាន (បញ្ញត្តិ គោលការណ៍ និងការប្រើប្រាស់ដី) ..........................................................36

៣.២.៣.២. ដីស្រែវស្សា និងស្រែប្រាំង ....................................................................................................36

៣.២.៣.៣. ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព....................................................................................37

៣.២.៣.៤. ការសាងសង់ស្ពានឆ្លងព្រែក និងទ្វារទឹក....................................................................................38

៣.២.៣.៥. ការប្រើប្រាស់ផ្លូវថ្នល់ ...........................................................................................................39

៣.២.៣.៦. ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ និង ទីតាំងសាលាថ្មី .............................................40

៣.២.៣.៧. ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន.........................................................41

**ឧបសម្ព័ន្ធ ១ :ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**........................................................43

**ឧបសម្ពន្ធ័ ២ : ស្ថានភាពការគ្រប់គ្រង និង ភាពកាប់ដីបច្ចុប្បន្ន**.........................................................50

**ឧបសម្ពន្ធ័ ៣ : បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា,មូលហេតុ,ដំណោះស្រាយ)** ................................51

**ឧបសម្ពន្ធ័ ៤ : ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និង ជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ** .................................................................................55

**ឧបសម្ពន្ធ័ ៥ : បញ្ជីគំរោង ឬ សកម្មភាព សំខាន់របស់ឃុំក្នុង រយៈ ១៥ ឆ្នាំ** ..........................................57

**ឧបសម្ព័ន៦ : ផែនទីប្រើប្រាស់ដីលំអិតក្នុងឃុំ**

**ឧបសម្ព័ន៧ : ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំ**

**ឧបសម្ព័ន៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគតក្នុងឃុំឆ្នាំ ២០០៩-២០២២**

# អារម្ភកថា

របាយការណ៍ស្តីអំពីផែនការប្រើប្រាស់ដីនៅក្នុងឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង ត្រូវបានរៀបចំឡើងដោយក្រុងប្រឹក្សាឃុំថ្មស និងមានចូលរួមពីគណៈកម្មការផែនការថវិកា ប្រជាពលរដ្ឋ ដោយមានកិច្ចសហការពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកបូទុមសាគរ (D-Lup) ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីខេត្ត កោះកុង (P-Lup) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាពរៀបចំដែនដី (Land Management) របស់អគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីកម្ម នៃក្រសួងដែនដី នគរូបនីយ៍កម្ម និង សំណង់ ក្រោមការជួយឧបត្ថមថវិកាពីអង្គការ (DANIDA,NFID, NZAID) តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការរៀបផែនការប្រើប្រាស់ដីធ្លីនៅក្នុងឃុំថ្មសជាត្រីវិស័យតំរង់ទិសដៅដល់ការអភិវឌ្ឍន៍ និងដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគឃុំ ឱ្យចំទិសដៅព្រមទាំងតំរូវការរបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និង គោលនយោបាយវិមជ្ឈការ និង សហវិមជ្ឈការ សំដៅពង្រឹងអភិបាល កិច្ចល្អរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដឱ្យកាន់តែប្រសើរឡើង ។

ក្នុងនាមក្រុមប្រឹក្សាឃុំអាណត្តិទី២ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មការផែនការថវិកា ជនបង្គោលប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសស្រាក់ស្រស្រាំដោយបានលើកឡើងពីបញ្ហា មូលហេតុជាក់ស្តែងនានាដែលបានជួបប្រទះ និងតំរូវការអភិវឌ្ឍន៍ ជាពិសេសចំពោះក្រសួងរៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់ និង អង្គការ DANIDA DFID NZAID ដែលបានផ្តល់ថវិកាជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់បញ្ចប់ ។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់មន្ទីររៀបចំ ដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តកោះកុង ដែលបានជួយសំរបសំរួលក្នុងការរៀបចំផែនការនេះឱ្យទទួលបានជោគជ័យ និងសូមថ្លែងអំណរគុណពីការចូលរួមរបស់មន្ទីរ អង្គភាពពាក់ព័ន្ធនានាជុំវិញខេត្ត ។

ក្រុមប្រឹក្សាឃុំថ្មសទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ទាំង អស់ និង បានយល់ដឹងអំពីស្ថានភាព និង តំរូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធនឹងការប្រើប្រាស់ដីក្នុងដំណើរការអភិវឌ្ឍន៍ឃុំថ្មស ហើយនឹងបង្ហាញនូវទឹកចិត្តសប្បុរសធមិដ៏ថ្លៃថ្លាតាមរយៈការចូលរួមផ្តល់នូវសំភារៈ និងថវិកាសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីធ្លីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។

ធ្វើនៅថ្មស,ថ្ងៃទី២៥ ខែ...៥.....ឆ្នាំ ២០០៩

មេឃុំ

រិត_ភួន

## សេចក្ដីផ្ដើម

ឃុំថ្មសជាឃុំមួយរបស់ស្រុកបូទុមសាគរដែលមានទីតាំងស្ថិតនៅខាងត្បូងឈៀងខាងលិច ដែលមានភូមិចំណុះចំនួន ០៥ និងមានផ្ទៃដីសរុប ២៤.៧៦២ ហិចតា ។ ឃុំថ្មសមានព្រំប្រទល់ :

- ខាងជើងជាប់ឃុំអណ្ដូងទឹក
- ខាងត្បូងជាប់ឆកសមុទ្រកំពង់សោម
- ខាងកើតជាប់ឆកសមុទ្រកំពង់សោម
- ខាងលិចជាប់ឃុំតានួន និង ឃុំភ្ញីមាស

### ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំមានគោលបំណង :

- រៀបចំគ្រប់គ្រងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព និង កាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីធ្លី ។
- គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំស្របតាមស្ថានភាពដីជាក់ស្ដែង និងសក្ដានុពល
- ឆ្លើយតបចំពោះសេចក្ដីត្រូវការរបស់អាជ្ញាធរនានា និងប្រជាពលរដ្ឋនៅក្នុងឃុំ
- ជួយការពារធនធានដីនិងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាពដី និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរបស់រដ្ឋ
- ស្វែងរកការគាំទ្របច្ចេកទេសពីស្ថាប័ន អង្គភាពនានា និង ពីផ្នែកឯកជនក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ ។

ការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅក្នុងឃុំថ្មសជាឧបករណ៍មួយដ៏សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និង សមធម៌ ព្រោះដីធ្លីជាកត្តាស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជីវភាពប្រជាពលរដ្ឋក្នុងឃុំទាំងមូល ។ ដូច្នេះក្រោយពីការរៀបចំផែនការប្រើប្រាស់ដីនេះរួចធ្វើអោយឃុំមានទិសដៅច្បាស់លាស់ក្នុងការធ្វើការងារអភិវឌ្ឍន៍ ឬ គំរោងសកម្មភាពនានាសំរាប់អាណត្តិនីមួយៗនៅថ្ងៃខាងមុខ មិនត្រឹមតែប៉ុណ្ណោះវាជាយុទ្ធសាស្ត្រមួយសំរាប់អាណត្តិបន្តបន្ទាប់រយៈពេល ១៥ ឆ្នាំក្រោយ ដោយផ្អែកលើបញ្ហា មូលហេតុ ដំណោះស្រាយ ដែលបានលើកឡើង និងធ្វើការប្រៀបធៀបទៅនឹងលទ្ធផលជាក់ស្ដែងជាមួយព័ត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ។

# ប្រវត្តិនៃឃុំថ្មស

តាមតំណាលពីបុរាណកាល ចាស់ៗជំនាន់មុនបាននិយាយតៗគ្នាមកថា កាលពីដើមឡើយនៅទីតាំងឃុំថ្មសទាំង មូលនេះគឺជាសមុទ្រដ៏ធំល្វឹងល្វើយគ្មានកោះត្រើយអ្វីទេ ។ នាជំនាន់នោះឈ្មួញសំពៅបានមករកស៊ីចេញ ចូល ឆ្លងកាត់តាមច្រកសមុទ្រនេះ លុះក្រោយមកសមុទ្រមុំថ្មសមានដីដុះកាន់តែរាកឡើង និងមានដុំថ្មមួយដុំដុះចេញឡើងផុតពីទឹកសមុទ្រកាលក្នុងគ្រានោះ ។ ដោយមានថ្មមួយដុំដែលមានទំហំប្រមាណទទឹងជាងមួយម៉ែត្រ បណ្តោយជាងពីរម៉ែត្រ ហើយអណ្តែតផុតពីទឹកនៅកណ្តាលសមុទ្របែបនេះ សត្វរំពេរ និង សត្វស្លាបផ្សេងទៀតដែលហើរស្វែងរកចំណី (សាច់ត្រី) បានសំរាកស្លាប ឬ ស្នាក់នៅទាំងយប់ទាំងថ្ងៃ សត្វសាបទាំងនោះបានជុះអាចម៍ដាក់លើដុំថ្មនេះ លុះយូរៗឆ្នាំទៅអាចម៍សត្វស្លាបក៏បានប្រឡាក់លើដុំថ្មស្ងួតជាប់ជាពណ៌ស នាយសំពៅ និង ឈ្មួញសំពៅក្រឡេកមើលឃើញហើយក៏ចាត់ទុកថាជាកន្លែងសំគាល់ផងនោះ ក៏ហៅឈ្មោះថា **ថ្មស** ។ ចំណេរតមកទីតាំងឃុំថ្មសនេះមានដីដុះដែលហូរចាក់ចុះមកពីភ្នំផង រលកសមុទ្រវាយបក់ចាក់គរផង ហើយដីនេះមានស្ថានភាពទំនាបស្មើអាចធ្វើស្រែចំការបាន និង ការធ្វើនេសាទបានផង ឈ្មួញសំពៅបាននាំបងប្អូនមករស់នៅប្រកបរបរកសិកម្ម ដាំដុះ និង នេសាទ ដោយប្រមូលផ្តុំបង្កើតទៅជាភូមិ និងដាក់ឈ្មោះថា **ភូមិថ្មស** ។

ដោយសង្គមជាតិចេះតែវិវត្តន៍តំរូវបង្កើតជាឃុំ ស្រុក ខេត្ត ដោយឡែក **ថ្មស** ជាឈ្មោះមួយបានកើតមុនគេក៏សំរេចដាក់ឈ្មោះថា **ឃុំថ្មស** ប្រើប្រាស់រហូតដល់សព្វថ្ងៃនេះទៅ ។

សូមបញ្ជាក់ថាបច្ចុប្បន្នដុំថ្មនេះស្ថិតនៅចំងាយប្រមាណ ២០០ ម៉ែត្រពីមាត់សមុទ្រ នៅជុំវិញថ្មគឺជាវាលស្រែដែលកសិករធ្វើស្រែវស្សាទទួលទានរៀងរាល់ឆ្នាំ ។ ដុំថ្មនេះស្ថិតនៅជាយខាងកើតភូមិថ្មសប្រមាណ ១.៥០០ ម៉ែត្រ ពីចំណុចកណ្តាលភូមិថ្មសតែប៉ុណ្ណោះ សព្វថ្ងៃថ្មសនេះមានទំហំប្រមាណទទឹង ២,៥០ ម៉ែត្រ បណ្តោយ ៤,៥០ ម៉ែត្រ កំពស់ប្រមាណ ២,៥០ ម៉ែត្រ ដែលអណ្តែតនៅលើដី ។

# ជំពូក ១

## ១.១. ស្ថានភាពទូទៅ

ឃុំថ្មសជាឃុំមួយក្នុងចំណោមឃុំទាំង ៤ ស្ថិតនៅស្រុកបូទុមសាគរ ខេត្តកោះកុង មានផ្ទៃដីសរុប២៤.៧៦២ ហត។ ឃុំថ្មស មានភូមិចំនួន ៥ គឺ ភូមិចំលងគោ ភូមិថ្មស ភូមិស្រែត្រាវ ភូមិស្រែថ្មី និង ភូមិចំការលើ ។ ឃុំថ្មស មានទីតាំងស្ថិតនៅប៉ែកខាងលិចឈៀងខាងត្បូង នៃស្រុកបូទុមសាគរមានចំងាយផ្លូវប្រមាណជា ៤៤ គីឡូម៉ែត្រ តាមបណ្តោយផ្លូវលំក្រាលគ្រួសក្រហមភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុចអូរម្កាក់ពីជើងទៅត្បូង ។ ឃុំថ្មសមានព្រំទល់ខាងជើងជាប់ឃុំអណ្តូងទឹក ខាងត្បូង និង ខាងកើតជាប់ឆកសមុទ្រកំពង់សោម ខាងលិចជាប់នឹងឃុំតានួន។

ពីអតីតកាលឃុំនេះមានផ្ទៃដី ព្រៃស្រោង ២/៣ នៅប៉ែកខាងជើងឈៀងខាងលិច សំបូរទៅដោយសត្វព្រៃគ្រប់ប្រភេទ និង ត្រី នៅប៉ែកខាងត្បូង និងខាងកើតសំបូរទៅដោយមច្ឆាជាតិសមុទ្រ ។ ពីទសវត្ស ឆ្នាំ ១៩៩៩ មកធនធានធម្មជាតិទាំងនេះត្រូវបានថយចុះជាបន្តបន្ទាប់ ។

បច្ចុប្បន្នអ្នកភូមិទូទាំងឃុំថ្មសមានប្រមាណ ៣២,០៧% ស្មើនឹង ៥៨៣គ្រួសារប្រកបធ្វើស្រែជាចំបង គ្រួសារធ្វើចំការរយៈពេលវែងជាចំបង ៨,៧៥% ស្មើនឹង ១៥៩គ្រួសារ គ្រួសារមានមុខរបរដំណាំរយៈពេលខ្លី និងដំណាំបន្លែចំនួន ៥,៥៤%ស្មើនឹង៩៩គ្រួសារ និងគ្រួសារប្រកបមុខរបរសេវាកម្មចំនួន ៨,៣៧% ស្មើនឹង ១៥២ គ្រួសារ ចំពោះទិន្នន័យស្រូវវស្សាជាមធ្យម ៣ តោន ក្នុង១ហ ត ដែលចាត់ទុកថាមានបរិមាណខ្ពស់បង្គួរ។

ប្រជាពលរដ្ឋជាអ្នកក្រីក្រនៅឃុំថ្មសមួយចំនួនដោយសារពួកគាត់ខ្វះខាតធនធានដើម្បីធ្វើការពង្រីកសេដ្ឋកិច្ចគ្រួសារលើការដាំដុះ ។ ការដាំដំណាំនៅរដូវប្រាំងពុំមានប្រភពទឹកសំរាប់ស្រោចស្រពគ្រប់គ្រាន់ទេ។

ការចិញ្ចឹមគោ ក្របី សំរាប់ការងារកសិកម្ម និង ជ្រូក មាន់ ទា ជាលក្ខណៈគ្រួសារជាមុខរបរបន្ទាប់បន្សំប៉ុណ្ណោះ គឺពុំអាចផ្គត់ផ្គង់ដល់កំលាំងអូសទាញក្នុងវិស័យកសិកម្ម និង ជីវភាពគ្រួសារនោះទេ។

ផែនទីបង្ហាញទីតាំង ឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង



### ១.១.១. ទីតាំងភូមិសាស្ត្ររដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កោះកុង | |
| ស្រុក/ក្រុង | បូទុមសាគរ | |
| ឃុំ/សង្កាត់ | ឈ្មោះ ថ្មស | លេខកូដ ៩០១០៤ |
| ចំនួនភូមិ | ៥ ភូមិ គឺ ភូមិថ្មស ភូមិចំលងគោ ភូមិស្រែត្រាវ ភូមិស្រែថ្មី និង ភូមិចំការលើ | |

- ឃុំនេះមានទីតាំងពីសាលាស្រុកបូទុមសាគរចំងាយប្រហែល ៤៧ គីឡូម៉ែត្រ ដោយចូលទៅត្រង់ចំណុចផ្លូវបំបែកពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុចអូរម្កាក់ទៅឃុំថ្មស ដែលមានព្រំប្រទល់ខាងត្បូងជាប់ឆកសមុទ្រកំពង់សោម ខាងលិចជាប់ឃុំតានួន ខាងកើតជាប់ឆកសមុទ្រកំពង់សោម និង ខាងជើងជាប់ឃុំអណ្តូងទឹក ។

### ១.១.២. ប្រជាសាស្ត្រ

ឃុំថ្មសមានប្រជាជនសរុបចំនួន ១០.០៧៣ នាក់ មាន ១.៨១៨ គ្រួសារ ក្នុងនោះស្ត្រីមានចំនួន ៥.០៧៨ នាក់ ក្នុងឆ្នាំ ២០០៨ ។ ដង់ស៊ីតេប្រជាជន ១ នាក់ស្មើ០,២៨គីឡូម៉ែត្រក្រឡា ។ ឃុំថ្មសប្រជាជនស្ទើរតែ ១០០% ជាជនជាតិ ខ្មែរ កាន់ពុទ្ធសាសនាព្រះពុទ្ធ និង មានជំនឿទៅលើការសែនព្រេនអរក្ខអ្នកតាផងដែរ។ ភូមិថ្មសមានប្រជាជនរស់នៅ ច្រើនជាង ។

**តារាងស្ថិតិប្រជាជនឃុំថ្មស ឆ្នាំ ២០០៨**

| ស្ថិតិតាមក្រុមអាយុ | ប្រុស (នាក់) | ស្រី (នាក់) | សរុប (នាក់) | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម ០-៥ ឆ្នាំ | 506 | 515 | 1021 | |
| អាយុ០៥ឆ្នាំ | 152 | 150 | 302 | អាយុចូលរៀនមត្តេយ្យ |
| អាយុ៦-១១ឆ្នាំ | 785 | 790 | 1575 | អាយុចូលរៀនបឋមសិក្សា |
| អាយុ ១២-១៤ឆ្នាំ | 436 | 436 | 872 | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុ ១៥-១៧ឆ្នាំ | 431 | 434 | 865 | អាយុចូលរៀនវិទ្យាល័យ |
| អាយុ១៨-២៤ឆ្នាំ | 547 | 560 | 1,107 | អាយុដែលត្រូវចូលរៀនមហាវិទ្យាល័យ |
| អាយុ២៥-៦០ឆ្នាំ | 1,847 | 1,880 | 3,727 | អាយុពេញពលកម្ម |
| អាយុក្រោម ៦១ ឆ្នាំឡើង | 291 | 313 | 604 | ចូលនិវត្តន៍ |
| ប្រជាជនសរុប | 4,995 | 5,078 | 10,073 | |
| ចំនួនគ្រួសារ | 1,818 | | | |

*(ប្រភព:ឯកសារព័ត៌មានស្ថានភាពឃុំ ២០០៨)*

### ១.១.៣. ភាពគ្មានដីធ្លី

គ្រួសារដែលមានដីស្រែតិចជាង ០១ ហិចតា មានចំនួន ៣១៤គ្រួសារ ស្មើនឹង ៥៣,៨៦% ដើម្បីអោយគ្រួសារទាំងនេះអាចផ្គត់ផ្គង់ជីវភាពគ្រប់គ្រាន់ ពួកគាត់ត្រូវរកបរនេសាទបន្តិចបន្តួចបន្ថែមចំពោះគ្រួសារដែលនៅជិតមាត់ឆ្នេរ និង

មានទូកនេសាទ ។ ក្រៅពីរដូវធ្វើស្រែចំពោះគ្រួសារដែលនៅឆ្ងាយពីឆ្នេរ និងពុំមានឧបករណ៏នេសាទត្រូវស៊ីឈ្នួល បេះបង្គារ ក្ដាម និង ធ្វើជាកម្មករសំណង់ និងកម្មករនេសាទ។




តារាងគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ ប្រ/ជ សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | មានដីស្រែតិចជាង ១ ហិកតា | ៣១៤ | ៥៨.៨៦ | |

*(ប្រភព:ឯកសារព័តិមានស្ថានភាពឃុំ ២០០៨)*

### ១.១.៤. ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋនៅឃុំថ្មសមានតែ ៣២,០៧ % តែប៉ុណ្ណោះដែលប្រកបរបរធ្វើស្រែ (មានតែស្រែវស្សា) ដោយ ពឹងផ្អែកលើទឹកភ្លៀងតែមួយមុខគឺធ្វើស្រែបានតែមួយរដូវ ។ ដោយឡែកគ្រួសារចំនួន ៤៩,១៧ % មានមុខរបរនេសាទ សមុទ្រ តែការប្រកបរបរនេះ បច្ចុប្បន្នពុំសូវទទួលបានទិន្នផលច្រើនទេ។ ក្រៅពីមុខរបរទាំងពីរខាងលើប្រជាជន ត្រូវរកប្រាក់ចំណូលបន្ថែមដោយប្រកបរបរមួយចំនួនដូចជាការប្រមូលទិញទិន្នផលនេសាទ ធ្វើចំការដំណាំ ធ្វើជាងសំណង់ លក់ដូរទំនិញនៅផ្សារ... ។ល ។

**តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំថ្មស**

| ល.រ | ប្រភេទមុខរបរ | គ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ | |
| | មុខរបរកសិកម្មជាចំបង | 1742 | 95,82 % | |

| | | | | |
|---|---|---|---|---|
| | ធ្វើស្រែចំបង | 583 | 32,07 % | ស្រែវស្សា ចំការស្រូវដាំ |
| | ដាំដំណាំរយៈពេលវែងជាចំបង | 159 | 8,75 % | ខ្នុរ. ស្វាយ. ចន្ទី. ចំការកៅស៊ូ សាវម៉ាវ |
| | ដាំដំណាំរយៈពេលខ្លីជាចំបង | 75 | 4,13 % | ឪឡឹក. ពោត |
| | ដាំបន្លែជាចំបង | 24 | 1,32 % | ត្រកួន.ស្ពៃ.ត្រសក់.ត្រប់ |
| | សេវាកម្មជាចំបង | 76 | 4,18 % | ដឹកជញ្ជូន |
| | មុខរបរចំរុះក្រៅពីខាងលើ | 92 | 5 % | លក់ដូរ លក់ផលនេសាទ |

*( ប្រភព:ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំ ឆ្នាំ ២០០៨)*

### ១.១.៥. ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំថ្មសមានសាលាចំនួន ០៩ សាលា ក្នុងនោះសាលាមតេយ្យ ០១ អគារ ០២ បន្ទប់ មានគ្រូបង្រៀន ០២ នាក់ ស្រីទាំង ០២ នាក់ សិស្សសរុប ១៦៩ នាក់ ។ សាលាបឋមសិក្សាមានចំនួន ០៧ អគារ ២៨ បន្ទប់ ថ្នាក់រៀនមានចំនួន ៤១ ថ្នាក់ មានគ្រូបង្រៀនចំនួន ៣៦ នាក់ និងមានសិស្សសរុប ១,៥០៨ នាក់ ។ សាលាអនុវិទ្យាល័យចំនួន ០១ អគារ ៥ បន្ទប់ មាន ៥ ថ្នាក់ មានគ្រូបង្រៀនចំនួន ៩ នាក់ សិស្សសរុបចំនួន ៨១៣ នាក់ ។

**តារាងស្ថិតិសាលា និងចំនួនសិស្សប្រចាំឆ្នាំ ២០០៨**

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សប្រុស | សិស្សស្រី | |
| ថ្នាក់មត្តេយ្យសិក្សា | 01 | 02 | 02 | 169 | 86 | 83 | 65% |
| ថ្នាក់បឋមសិក្សា | 07 | 28 | 41 | 1,508 | 754 | 754 | 4% |
| ថ្នាក់អនុវិទ្យាល័យ | 01 | 05 | 05 | 813 | 414 | 399 | 7% |
| ថ្នាក់វិទ្យាល័យ | 0 | 0 | 0 | 680 | 337 | 343 | 21% |

*( ប្រភព:ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំ ឆ្នាំ ២០០៨)*

- ខ្វះគ្រូបង្រៀនគ្រប់កំរិតសិក្សា
- ពុំទាន់មានសាលារៀនគ្រប់គ្រាន់ និង គ្រប់កំរិតសិក្សា
- ដោយឡែកចំពោះសិស្សដែលបញ្ចប់ការសិក្សាពីថ្នាក់អនុវិទ្យាល័យ សិក្សានៅឃុំថ្មសនោះត្រូវជួបបញ្ហាដោយសិស្សត្រូវបន្តទៅរៀននៅវិទ្យាល័យអណ្ដូងទឹកដែលមានចំងាយ ៤៧ Km ដូចនេះចំពោះសិស្សដែលក្រីក្រត្រូវបោះបង់ចោលការសិក្សា ។ បញ្ហាវិទ្យាល័យឃុំថ្មសនៅពុំទាន់សាងសង់នៅឡើយទេ ប៉ុន្តែបច្ចុប្បន្នឃុំមានគម្រោងធ្វើអគារ ១ ខ្នង ៥ បន្ទប់ ។

### ១.១.៦. ស្ថានភាពសុខាភិបាល

#### ១.១.៦.១. ផ្នែកសុខាភិបាល

ស្ថានភាពសុខភាពរបស់ប្រជាជនក្នុងឃុំមិនទាន់ចាត់ទុកថាល្អប្រសើរនៅឡើយទេ ដោយប្រជាពលរដ្ឋមួយចំនួនខ្វះការយល់ដឹងពីសុខភាពខ្វះអនាម័យក្នុងការប្រើប្រាស់ម្ហូបអាហារ និង ទឹកស្អាត ។

មណ្ឌលសុខភាពនៅឃុំថ្មសមាន ០១ កន្លែង ដែលមានគ្រូពេទ្យចំនួន ០៣ នាក់ ក្នុងនោះពេទ្យឆ្មបចំនួន ០១ នាក់ និងឆ្មបបូរាណចំនួន ១៩ នាក់ ។ ការផ្តល់ថ្នាំបង្ការ ប្រជាជនពុំសូវយកចិត្តទុកដាក់នៅឡើយ ។ នៅមណ្ឌលសុខភាពបច្ចុប្បន្នមានអាគារឈើសំរាប់សំរាលកូន ២ បន្ទប់គឺមិនគ្រប់គ្រាន់តាមតំរូវការសំរាប់សំរាលកូននៅឡើយទេ ។ ចំពោះស្ថានភាពជំងឺដែលកាចសាហាវនៅក្នុងឃុំដូចជាជំងឺរបេង ថ្លើម អេដស៍ គ្រុនចាញ់ ។ ល។ បច្ចុប្បន្នសេវាសុខភាពនៅឃុំថ្មសពុំទាន់បំពេញបានទេនូវសេចក្តីត្រូវការរបស់ប្រជាជនទូទាំងឃុំបាននៅឡើយ ដោយឡែកឃុំថ្មសក៏ពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិជួយសំរួលដល់ការទ្រទ្រង់សុខមាលភាពរបស់ប្រជាជនបន្ថែមលើមណ្ឌលសុខភាពទេ ។ ចំងាយជាមធ្យមពីភូមិដាច់ស្រយ៉ាលទៅមណ្ឌលសុខភាពមានប្រមាណពី ១២ គ.ម ទៅ ២១ គ.ម (ការដឹកជញ្ជូនអ្នកជំងឺមកមណ្ឌលសុខភាពត្រូវប្រើបធ្យោបាយផ្ទាល់ខ្លួន) ។

**តារាងស្ថិតិ មណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ**

| មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|
| | ចំនួនមណ្ឌល | គ្រែ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណតាមភូមិ |
| មណ្ឌលសុខភាព | 01 | 02 | 03 | 01 | 19 នាក់ |
| ប៉ុស្តិ៍សុខភាពភូមិ | 0 | 0 | 0 | 0 | 0 |

*(ប្រភព: មណ្ឌលសុខភាពឃុំថ្មស)*

#### ១.១.៦.២. ការផ្គត់ផ្គង់ទឹកស្អាត

ប្រភពនៃការប្រើប្រាស់ទឹកស្អាតពុំទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំនៅឡើយទេ ទោះបីប្រជាពលរដ្ឋឃុំនេះភាគច្រើនប្រើទឹកអណ្តូងដែលជាប្រភពដ៏សំខាន់ក៏ដោយ ក៏នៅតែមានកង្វះខាតទឹកស្អាតដដែលដោយទឹកមានការរីងរាក់នៅរដូវប្រាំង ទឹកអណ្តូង និង ទឹកស្រះ របស់ប្រជាជនដែលនៅឆ្ងាយប្រភពទឹកមិនអាចរក្សាទឹកទុកប្រើប្រាស់បានយូឡើយ ។

ចំពោះអណ្តូងល្អដែលបានប្រើពេញ ១ ឆ្នាំ មានចំនួន ២២ អណ្តូង និង អណ្តូងមិនអាចប្រើប្រាស់មានចំនួន ២៧ អណ្តូង ។ ដោយឡែកអណ្តូងដែបានប្រើពេញ ០១ ឆ្នាំមានចំនួន ៧០ អណ្តូង និង អណ្តូងដែមិនទាន់ដាក់ល្ងូ ឬ មិនរៀបតដ្ឋមិនអាចប្រើបាននៅរដូវប្រាំចំនួន ៣៨ អណ្តូង ។ ដោយឡែកចំពោះអណ្តូងល្ងូ និង អណ្តូងដែមួយចំនួនគ្មានទឹក ហើយបើសិនជាមានទឹកក៏ទឹកនោះក៏មិនអាចប្រើប្រាស់បានទេ ដូច្នេះត្រូវស្តារឡើងវិញទាំងស្រុង ។



**តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំថ្មស**

| ល.រ | ប្រភេទអណ្តូង | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើប្រាស់ | ខូចខាត | |
| ១ | អណ្តូងស្នប់ | 0 | 0 | 0 | |
| ២ | អណ្តូងលូ | 49 | 22 | 27 | ខូចត្រូវស្តារឡើងវិញ |
| ៣ | អណ្តូងដៃមិនដាក់លូ | 70 | 32 | 38 | ខូចរេចរិល៣៨ រាក់ប្រើលែងកើត |
| ៤ | ស្រះទឹក | 5 | 2 | 3 | ១រាក់គ្មានទឹកល្អសំរាប់ប្រើ |

*( ប្រភព:ឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំ ឆ្នាំ ២00៨)*

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំថ្មសភាគច្រើនជាតំបន់ភ្នំដែលគ្របដណ្តប់ដោយព្រៃឈើ និង តំបន់មួយចំនួនទៀតជាតំបន់ទំនាបវាលស្មៅព្រៃលិចទឹក និងទំនាបឆ្នេរសមុទ្រ ។ ឃុំថ្មសស្ថិតនៅប៉ែកខាងត្បូងនៃស្រុកបូទុមសាគរ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងឃុំអណ្តូងទឹក ខាងកើត និងខាងត្បូងជាប់នឹងមាត់សមុទ្រ និងខាងលិចជាប់នឹងឃុំតានូន ។

### ១.២.២. រយៈកំពស់

ឃុំថ្មសជាទូទៅមានរយៈកំពស់ខ្ពស់នៅត្រង់ផ្នែកកណ្តាលចាប់ពីទិសខាងជើងឆ្ពោះទៅទិសខាងត្បូងដែលមានកំពស់ចាប់ពី ៦៥-១៦0 ម៉ែត្រ និង តំបន់ទំនាបលិចទឹកនៅទិសខាងជើងឈាងខាងលិច ព្រមទាំងទំនាបឆ្នេរនៅទិសខាងកើតឈាងខាងត្បូង ដែលមានកំពស់ចាប់ពី 0-៦៥ ម៉ែត្រ ។

ផែនទីរយៈកំពស់ ក្នុងឃុំថ្មស




### ១.២.៣. អាកាសធាតុ :

ឃុំថ្មសមានលក្ខណៈអាកាសធាតុក្តៅហើយសើម មានរដូវពីរច្បាស់លាស់គឺរដូវប្រាំង និង រដូវវស្សា ។ រដូវប្រាំងចាប់ពីខែ វិច្ឆិកា ដល់ ខែមេសា និង រដូវវស្សាចាប់ពី ខែឧសភា ដល់ ខែតុលា ។ មានកំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ :

- ឆ្នាំ ២០០៦ កំពស់ទឹកភ្លៀងខ្ពស់នៅខែមេសា ឧសភា មិថុនា សីហា កញ្ញា និង ខែ តុលា និង កំពស់ខ្ពស់បំផុតនៅខែសីហា ហើយកំពស់សរុបប្រចាំឆ្នាំមាន ៣,២២២.៦៩ មម ។
- ឆ្នាំ ២០០៧ កំពស់ទឹកភ្លៀងខ្ពស់នៅខែ ឧសភា មិថុនា កក្កដា សីហា កញ្ញា និង ខែ តុលា និង កំពស់ខ្ពស់បំផុតនៅខែកក្កដា ហើយកំពស់សរុបប្រចាំឆ្នាំមាន ២,០២១.៦១ មម ។
- ឆ្នាំ ២០០៨ កំពស់ទឹកភ្លៀងខ្ពស់នៅខែ មិនា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា និង ខែ វិច្ឆិកា និង កំពស់ខ្ពស់បំផុតនៅខែ មិថុនា ហើយកំពស់សរុបប្រចាំឆ្នាំមាន ២,៣០៤.៤៣ មម ។

*(ទិន្នន័យបានមកពីមន្ទីរធនធានទឹក និងឧតុនិយមខេត្ត)*




### ១.២.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ដឹកជញ្ជូន

ឃុំថ្មសជាឃុំមួយដែលជាប់នឹងឆ្នេរសមុទ្រ និង តំបន់ភ្នំ នៅរដូវវស្សា និង រដូវប្រាំងការធ្វើដំណើរតាមផ្លូវទឹកអាចចេញចូលបានដោយងាយដោយសារទីប្រជុំជនឃុំនៅជាប់ឆ្នេរសមុទ្រ ។

ឃុំថ្មសមានផ្លូវក្រាលគ្រួសក្រហមមួយខ្សែភ្ជាប់ពីឃុំអណ្តូងទឹកត្រង់ចំណុចព្រែកក្រូចមានប្រវែង ៣០.១៦គីឡូ ម៉ែត្រ ។ ចំពោះផ្លូវលំដីសមានប្រវែង ១៦.២៥ គីឡូម៉ែត្រ និងផ្លូវលំធម្មតាប្រវែង ៧៤.៣០ គីឡូម៉ែត្រ ។

ឃុំថ្មសមានកំពង់ផែខ្នាតតូចចំនួន ០១ កន្លែងដែលប្រើប្រាស់ក្នុងការចូលចតទូក និងងាយស្រួលក្នុងការដឹកជញ្ជូនទំនិញចេញចូលមកខេត្តព្រះសីហនុ និង តំបន់ផ្សេងៗទៀត ។



## ១.៣. ស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១. ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំថ្មសអាចចែកចេញជា ៦ ប្រភេទ សាមញ្ញគឺជាដីលំនៅដ្ឋាន ដីកសិកម្ម ដីព្រៃឈើ ដីព្រៃកោងកាង ដីវាលស្មៅ និងផ្ទៃទឹក ។

**តារាងប្រភេទប្រើប្រាស់ដីលំអិត**

| ល.រ | កូដ | ប្រភេទការប្រើប្រាស់ដី | ក្រឡាផ្ទៃ(ហត) | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | 1100 | ដីលំនៅដ្ឋានទីប្រជុំជន | 15.49 | 0.06 | |
| 2 | 1200 | ដីលំនៅដ្ឋានភូមិ | 409.93 | 1.65 | |
| 3 | 1300 | ហេដ្ឋារចនាសម្ព័ន្ធ | 17.56 | 0.07 | |
| 4 | 2110 | ដីស្រូវវស្សា | 556.96 | 2.24 | |
| 5 | 2113 | ដីស្រែខ្វះជីរជាតិ | 36.66 | 0.14 | |
| 6 | 2200 | ដីដំណាំចំការ | 158.01 | 0.63 | |
| 7 | 2310 | ដីចំការឈើហូបផ្លែ | 2,359.51 | 9.52 | |
| 8 | 2311 | ដីចំការឈើហូបផ្លែលើដីភូមិចាស់ | 141.71 | 0.57 | |
| 9 | 2321 | ដីចំការកៅស៊ូ | 2.77 | 0.01 | |
| 10 | 2323 | ដីចំការស្វាយចន្ទី | 17.12 | 0.06 | |
| 11 | 2400 | ដីកសិកម្មពនេចរ | 45.90 | 0.18 | |
| 12 | 3110 | ដីព្រៃស្រោង | 8,924.99 | 36.04 | |
| 13 | 3210 | ដីព្រៃរបោះ | 11.86 | 0.04 | |
| 14 | 3220 | ដីព្រៃរបោះ(ស្តើងស្ងួត) | 8.07 | 0.03 | |
| 15 | 3300 | ដីព្រៃចំរុះ(ស្រោង និង របោះ) | 59.48 | 0.24 | |
| 16 | 3310 | ដីព្រៃដុះតាមមាត់ទឹក | 18.91 | 0.07 | |
| 17 | 3400 | ដីព្រៃដុះឡើងវិញ | 510.75 | 2.06 | |
| 18 | 3500 | ដីព្រៃលិចទឹក | 1,470.34 | 5.93 | |
| 19 | 3510 | ដីព្រៃលិចទឹក(ក្រាស់) | 796.08 | 3.21 | |
| 20 | 3600 | ដីព្រៃកោងកាង | 369.43 | 1.49 | |
| 21 | 3610 | ដីព្រៃកោងកាងស្តើង | 1,009.52 | 4.07 | |
| 22 | 3800 | ល្បាយដីលាយដីកសិកម្ម | 40.56 | 0.16 | |

| | | | | | |
|---|---|---|---|---|---|
| 23 | 3820 | ដីល្បាយព្រៃលាយដីចំការ | 836.85 | 3.37 | |
| 24 | 4110 | ដីវាលស្មៅ | 3,222.60 | 13.01 | |
| 25 | 4110 | ដីចំការបោះបង់ដុះស្មៅ | 167.79 | 0.67 | |
| 26 | 4200 | ដីវាលស្មៅលិចទឹក | 190.94 | 0.77 | |
| 27 | 4500 | ដីព្រៃគម្ពោធ | 1,360.17 | 5.49 | |
| 28 | 5510 | ដីចំការបោះបង់ដុះព្រៃគម្ពោធ | 83.73 | 0.33 | |
| 29 | 4600 | ដីព្រៃគម្ពោធលាយដីឈើធំមួយៗ | 1,083.77 | 4.37 | |
| 30 | 5120 | អាងទឹក ឬទំនប់ | 0.64 | 0.002 | |
| 31 | 5130 | ស្រះទឹក | 0.08 | 0.00 | |
| 32 | 5210 | បឹងស្ទឹងអូរ | 91.11 | 0.36 | |
| 33 | 5220 | ផ្ទៃសមុទ្រ | 488.99 | 1.97 | |
| 34 | 5300 | ដីវាលភក់ | 9.16 | 0.03 | |
| 35 | 6200 | ដីខ្សាច់ | 33.27 | 0.13 | |
| 36 | 6300 | ផ្ទាំងថ្មដុះពីដី | 0.13 | 0.0005 | |
| 37 | 6420 | ដីព្រៃកាប់ឆ្ការ | 211.76 | 0.85 | |
| | **ផ្ទៃដីសរុប** | | **24,762** | | |

### ១.៣.២. ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី

ស្ថានភាពនៃការកាន់កាប់ដី និងគ្រប់គ្រងដីនៅក្នុងឃុំថ្មស ក្រៅពីលំនៅដ្ឋាន ដីស្រែចំការ ដែលជាកម្មសិទ្ធិរបស់ឯកជនគឺសុទ្ធសឹងជាដីសាធារណៈរបស់រដ្ឋដែលស្ថិតនៅក្រោមរូបភាពមួយចំនួនដូចជា :

- តំបន់ការពាររបស់ឧទ្យានជាតិបូទុមសាគរ ដែលចេញដោយព្រះរាជក្រឹត្យឆ្នាំ ១៩៩៣ ស្ថិតក្នុងឃុំថ្មសទំហំសរុប ២៣.២៩០.៨៦ ហ.ត ។
- ដីសហគមន៍នេសាទ (ពុំទាន់មានការទទួលស្គាល់ជាផ្លូវការ)
- ដីក្រុមហ៊ុនអភិវឌ្ឍន៍ទីក្រុង ក្រុមហ៊ុន Union Development Group Co.,Ltd មានទំហំប្រមាណ ២.៦៩៤.៦៧ ហ.ត ស្ថិតក្នុងឃុំថ្មស ។ បច្ចុប្បន្នមានប្រជាជនជាច្រើនបានកាប់រានទន្រ្ទានយកដីព្រៃធ្វើជាកម្មសិទ្ធិ ក្នុងតំបន់ឧទ្យានជាតិ បុទុមសាគរ និង ដកហូតផលអនុផលព្រៃឈើហួសកំរិត ហើយមានភ្លើងឆេះព្រៃជារឿង រាល់រដូវប្រាំង ដែលបង្កឡើងដោយមនុស្ស ទោះជាមានការហាមឃាត់ពីមន្រ្តីឧទ្យានជាតិយ៉ាងណាក៏ដោយ ។

តារាងសង្ខេបស្ថានភាពកាន់កាប់ និងគ្រប់គ្រងដី

| ល.រ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហ.ត) | ផ្សេងៗ |
|---|---|---|---|
| 1 | តំបន់ការពារឧទ្យានជាតិបូទុមសាគរ | 23,290.86 | |
| 2 | ដីសហគមន៍នេសាទ | 10,664.00 | |
| 3 | ដីក្រុមហ៊ុនអភិវឌ្ឍន៍ទីក្រុង ( Union Development Group Co.,Ltd ) | 2,654.67 | |
| 4 | ដីបំរុងបង្កើតសហគមន៍ព្រៃឈើ | 1,357.00 | |

**១.៣.៣. ផលិតកម្មកសិកម្ម**

នៅក្នុងឃុំថ្មសមានផ្ទៃដីកសិកម្មចំនួន ២,៩១៦.៤៨ ហិចតា ក្នុងនោះដីស្រែវស្សា ៥៥៦.៩៦ ហិចតា បានដាំស្រូវវស្សាជាក់ស្តែង ៣០០ហិចតា ស្មើ ៥៣.៨៦ % ។ ឃុំថ្មសបង្កបង្កើនផលស្រូវបានតែមួយរដូវ ប៉ុណ្ណោះគឺរដូវវស្សា ទិន្នផលស្រូវវស្សាជាមធ្យមក្នុង ១ហិចតា ៣ តោន ។

- ផ្ទៃដីចំការស្រូវទំហំ ៥៥ ហិចតា ដោយទទួលផលស្រូវ១ហិចតា ២ តោន
- ផ្ទៃដីចំការឈើហូបផ្លែទំហំ ២,៣៥៩.៥១ហិចតា ក្នុងនោះមានចំការដូង ស្វាយចន្ទី ស្វាយ ធូរេន សាវម៉ាវ...ល។

**តារាងប្រភេទកសិកម្មសំខាន់ៗ និងទិន្នផលទទួលបានឆ្នាំ ២០០៨**

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី ហ.ត | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប ហ.ត | ដាំបានគិតជាភាគរយ | ផលសរុប (តោន) | ទិន្នផល (តោន/ហ.ត) |
| ១ | ដំណាំស្រូវ | 300.00 | 53.86 | 900.00 | 3.000 គ.ក្រ |
| ២ | ដំណាំស្រូវចំការ | 55.00 | 100 | 110.00 | 2.000 គ.ក្រ |
| ៣ | ចំការឈើហូបផ្លែ | 2,359.52 | | | |
| ៤ | ដំណាំរួមផ្សំ | 558.00 | | | |

*(ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៨ និង ផ្នែកGIS)*

- បច្ចុប្បន្នការងារកសិកម្មដូចបានរៀបរាប់ខាងលើ គឺប្រជាពលរដ្ឋធ្វើស្រែចំការពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ។ ឃុំមានគំរោងដំណើរការស្តារប្រឡាយ លើកទំនប់ការពារទឹកប្រៃ និងឱ្យប្រជាពលរដ្ឋជ្រើសពូជស្រូវដែលមានទិន្នផលខ្ពស់ ប្រើប្រាស់ជីរធម្មជាតិដើម្បីកែប្រែដីឱ្យមានគុណភាពខ្ពស់បំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងភូមិ និង ឃុំទាំង មូល ។

### តារាងក្រឡាផ្ទៃតាមផលិតភាពដី និងការប្រើប្រាស់ផលិតផល

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីវជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា (ហ.ត) |
|---|---|---|---|
| 1 | **ដីមានផលិតភាពទាប** | **ល្បាយខ្សាច់** | |
| | ដីលំនៅដ្ឋាន | សំណាប ស្វាយ ដូង ទៀប ខ្នុរ មៀន ស្លឹកគ្រៃ ននោង ស្ពៃ ត្រកួន ម្ទេស ត្រប់ | 357.25 |
| | ដីស្រែវស្សា | ស្រូវសូម៉ាលី ស្រូវស ស្រូវឡើកវ៉ាយ | 556.88 |
| | ដីចំការបោះបង់ដុះស្មៅ | | 161.54 |
| | ដីចំការដំណាំ | ចន្ទីរ ខ្នុរ ស្វាយ ទៀប ននោង ត្រលាច ល្ពៅ ស្ពៃ ពោត ឱឡឹក ត្រប់ ត្រកួន ត្រសក់ | 158.00 |
| | ដីចំការបោះបង់ដុះព្រៃគម្ពោធ | | 83.73 |
| | ដីចំការចន្ទីរ | | 17.11 |
| | ព្រៃកាប់ឆ្ការ | ចន្ទីរ , ដូង , កៅស៊ូ... | 211.75 |
| | ព្រៃរបោះ | | 11.85 |
| | ព្រៃរបោះ(ស្តើងស្ងួត) | | 8.00 |
| | ព្រៃលិចទឹក | ស្នាច់ , ដើមបឹស,... | 1,199.70 |
| | ព្រៃលិចទឹកក្រាស់ | | 426.55 |
| | វាលស្មៅលិចទឹក | | 70.79 |
| | ល្បាយដីព្រៃលាយដីកសិកម្ម | | 40.56 |
| | ល្បាយដីព្រៃលាយដីចំការ | | 836.76 |
| | ដីចំការឈើហូបផ្លែលើដីភូមិចាស់ | | 35.21 |
| | វាលស្មៅ | | 1,675.85 |
| | ដីហេដ្ឋារចនាសម្ព័ន្ធ | វត្ត, សាលារៀន , សាលាឆទាន ,សាលាឃុំ... | 17.48 |
| | ដីព្រៃកោងកាង | កោងកាង , ក្រញូប , តាបុន... | 223.64 |
| | វាលភក់ | | 9.12 |
| | ព្រៃចំរុះ | | 59.48 |
| | ព្រៃស្រោង | | 7,286.27 |
| | ចំការឈើហូបផ្លែ | ស្វាយ , ចន្ទីរ , ធុរេន , ខ្នុរ , សាវម៉ាវ... | 2,320.22 |

| | | | |
|---|---|---|---|
| | ស្រះ | | 0.08 |
| | ព្រៃកោងកាងស្តើង | កោងកាង , ក្រញឹប , តាបុន... | 936.53 |
| | ចំការព្រៃដាំ | ខ្លឹមច័ន្ទ , កៅស៊ូ , អាកាស្យា | 6.53 |
| | អាងស្តុកទឹក | | 0.63 |
| | ដីស្រែខ្សោះជីវជាតិ | | 12.00 |
| | ព្រៃដុះតាមមាត់ទឹក | | 12.38 |
| | អូរ ឬស្ទឹង | | 62.00 |
| | ចំការកៅស៊ូ | | 2.76 |
| | ឆ្នេរខ្សាច់ | | 30.00 |
| | ព្រៃដុះឡើងវិញ | | 79.59 |
| | ព្រៃគម្លោធ | | 1,073.93 |
| | ព្រៃ គម្លោធលាយដើមឈើធំមួយៗ | | 825.85 |
| | កសិកម្មពនេចរ | | 54.90 |
| | ដីលំនៅដ្ឋានប្រជុំជន | | 12.28 |
| | ដីស្រែវស្សា | | 556.88 |
| 2 | **ដីមានផលិតភាពមធ្យម** | **របាយគ្រួសក្រហម និង របាយក្រហម** | |
| | ដីលំនៅដ្ឋាន | ចេក ដូង ស្វាយ ខ្នុរ ទៀប មៀន ពោត កៅស៊ូ ត្របែក ចំពីងរាជ | 357.25 |
| | ដីស្រែខ្សោះជីវជាតិ | សូម៉ាលី ស្រូវស ស្រូវឡើកវាយ | 24.52 |
| | ដីព្រៃកោងកាងស្តើង | កោងកាង | 57.47 |
| | ដីព្រៃលិចទឹកក្រាស់ | ស្មាច់ ក្រញឹប តាប៊ុន តាអោន គគីរខ្សាច់ | 369.52 |
| | វាលស្មៅ | ស្បូវ ស្មៅ | 1546.74 |
| | វាលស្មៅលិចទឹក | កក់ កាថ្លុង ស្មៅ | 120.14 |
| | ដីចំការឈើហូបផ្លែលើដីភូមិចាស់ | ចេក ដូង ស្វាយ ទៀប ខ្នុរ កៅស៊ូ មៀន ចន្ទីរ | 106.49 |
| | ដីចំការបោះបង់ដុះស្មៅ | ដីល្បាយគ្រួសក្រហម និង ដីល្បាយខ្សាច់ | 6.42 |
| | ព្រៃលិចទឹក | ស្មាច់ ក្រញឹប កាប៊ុន តាអោន គគីរខ្សាច់ | 270.64 |
| | ដីចំការឈើហូបផ្លែ | ចេក ដូង ស្វាយ ទៀប ខ្នុរ កៅស៊ូ មាន ចន្ទីរ | 34.53 |

| | | | |
|---|---|---|---|
| | ដីព្រៃកោងកាង | កោងកាង | 72.41 |
| | ល្បាយដីព្រៃ លាយដីចំការ | | 0.08 |
| | អូរឬ ស្ទឹង | | 29.00 |
| | ព្រៃដុះឡើងវិញ | | 431.00 |
| | ព្រៃគម្ពោធ | | 283.00 |
| | ព្រៃគម្ពោធ លាយដើមឈើធំមួយៗ | | 258.00 |
| | ព្រៃស្រោង | គគីរខ្សាច់ ដូនចែម ត្រាច ធ្នុង ព្រូល ចំរ៉ាស់ ផ្ចឹកឧត្តម កំញ្ចាណ ផ្ទៀក នាងនួន បាយ ពូរាំង ឈើទាល ... | 1,638.71 |




*( ប្រភព: ផ្នែក GIS នៃមន្ទីរ ជនសស ខេត្តកោះកុង)*

### ១.៣.៤. ធនធានធម្មជាតិ

#### ១.៣.៤.១. ធនធានព្រៃឈើ

នៅឃុំថ្មសទាំងមូលមានធនធានព្រៃឈើទំហំសរុប ១៣.១៧៩.៤៥ ហិចតា ដែលស្ថិតនៅក្នុងតំបន់អភិរក្សឧទ្យានជាតិបុទុមសាគរ ។ ព្រៃឈើទាំងនេះបានផ្តល់សក្តានុពលមួយចំនួនសំរាប់ប្រយោជន៍សាធារណៈដូចជា ដូនចែម គគីរខ្សាច់ ត្រាច ថ្នុង ឈើទាល ថ្នឹកឧត្តម កំញ្ជាណ ផ្ដៀក បាយពូវាំង ព្រួស ចំម៉ាស់ ...។ល។ អនុផលព្រៃ ឈើមានដូចជាផ្តៅ វល្លិ៍រមៀត វល្លិ៍អន្ទង កន្ទុយដំរី ផ្សិតគគីរ ផ្លែសេមាន់ ផ្លែសំរង ផ្លែគុយ ផ្លែព្រួស ផ្លែផ្សៀវ ផ្លែគ្រៀល ...។ ល ។ ប្រភេទសត្វព្រៃមានដូចជា ជ្រូកព្រៃ ឈ្លូស ប្រើស ជ្រូកព្រូល កាំប្រមា អណ្តើក កន្ធាយ បង្រូល ត្រកួត អន្សង កន្រ្តង សំពោច ទន្សាយ ស្វា ពស់វែកដំបូក ពស់វែករនាម ទោចជាពិសេស ដំរី ខ្លាដំបង ខ្លារខិន ខ្លាឃ្មុំ ក្រពើ ត្រីនាគ...។ល។ ប្រភេទសត្វស្លាបមានដូចជា ពូវាំង កងកេង ត្រដក់ កុកក្រៀល ប្រវឹក ទាព្រៃ ក្ងោក មាន់ទឹក ស្ទាំង ភេ ...។ល។

#### ១.៣.៤.២. ធនធានជលផល

ភាគខាងត្បូង និង ខាងកើតឈៀងខាងលិចនៃឃុំថ្មសគឺជាតំបន់ឆ្នេរសមុទ្រជាប្រភពផ្តល់ធនធានជលផលដ៏ សំខាន់ ។ ដែនសមុទ្រ ក្បាលព្រែក បឹង ត្រពាំង ទាំងអស់នៃឃុំថ្មសសំបូរទៅដោយមច្ឆាជាតិដូចជា ត្រីរ៉ស់ ត្រីផ្ទក់ ត្រីឆ្តោ ត្រីក្រាញ់ ត្រីឆ្លាត ត្រីកន្ធប់ ត្រីកំភ្លាញ (ត្រីទឹកសាប)...។ល។ ត្រីឆ្កុង បង្គារ មឹក ក្តាមថ្ម ក្តាមសេះ គ្រែងឈាម ខ្យងហូល ត្រីផ្សោត ត្រីឆ្លាម ត្រីកាម៉ុង ត្រីការ៉ាវ ត្រីចាប (មច្ឆាសមុទ្រ).....។ល។



## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១. ទីផ្សារ និងតំលៃកសិផល អនុផលព្រៃឈើ និងផលនេសាទ

នៅក្នុងឃុំថ្មសដោយគិតពីតំលៃលក់ចេញនូវផលិតផល និង តម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ មានដូចតារាងខាងក្រោមនេះ :

| ល.រ | ឈ្មោះ | គីឡូក្រាម | ម៉ែត្រគូប (ស្ទែរ) | តម្លៃ (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | គ្រែងឈាម | 1 គ.ក្រ | | 3,500 | |
| 2 | បង្គារ | 1 គ.ក្រ | | 11,000 | |
| 3 | ត្រីឆ្លង់ | 1 គ.ក្រ | | 15,000 | |
| 4 | ត្រីក្បក | 1 គ.ក្រ | | 4,500 | |
| 5 | ត្រីកាម៉ុង | 1 គ.ក្រ | | 2,000 | |
| 6 | ស្រូវ | 1 គ.ក្រ | | 600 | |
| 7 | ខ្យងហូល | 1 គ.ក្រ | | 2,000 | |
| 8 | បង្កង | 1 គ.ក្រ | | 23,000 | |
| 9 | ត្រីក្រាញ | 1 គ.ក្រ | | 7,000 | |
| 10 | ក្តាមថ្ម | 1 គ.ក្រ | | 15,000 | |
| 11 | ក្តាមសេះ | 1 គ.ក្រ | | 8,000 | |
| 12 | ឈើប្រភេទលេខ ១ | | 1 ម$^3$ | 1,200,000 | |
| 13 | ឈើប្រភេទលេខ ២ | | 1 ម$^3$ | 1,000,000 | |
| 14 | ឈើប្រភេទលេខ ៣ | | 1 ម$^3$ | 800,000 | |
| 15 | ឈើកៅស៊ូលំដាប់ថ្នាក់ | | 1 ម$^3$ | 400,000 | |
| 16 | ត្រីរ៉ស់ | 1 គ.ក្រ | | 1,1000 | |
| 17 | ត្រីអណ្តែង | 1 គ.ក្រ | | 8,000 | |

### ១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល

នៅក្នុងឃុំថ្មសប្រជាពលរដ្ឋភាគច្រើនជាអ្នកមានមុខរបរនោសទសមុទ្រ និងទឹកសាប ហើយការអនុវត្តន៍ទៅតាមស្ថានភាពរបស់អ្នកនេសាទ ដែលក្នុងនោះប្រជាពលរដ្ឋរស់នៅតាមដងព្រែក និង ឆ្នេរសមុទ្រមានសកម្មភាពដូចខាងក្រោម :

- ឈ្មួញប្រមូលទិញពីអ្នកនេសាទមកស្តុកទុកនៅក្នុងស្តង់
- ឈ្មួញប្រមូលទិញផលនេសាទពីស្តង់យកទៅលក់នៅខេត្តព្រះសីហនុ ទីរួមខេត្តកោះកុង រាជធានីភ្នំពេញ ប្រទេសវៀតណាម និង ប្រទេសថៃ ។

- ផលដំណាំឈើហូបផ្លែមានដូចជា:ស្វាយ ដូង ខ្នុរ សាវម៉ាវ កំពីងរាជ ...លផលិតផលទាំងនេះបានលក់ដូរតែក្នុង មូលដ្ឋានប៉ុណ្ណោះ ។ មិនទាន់បានទទួលទិន្នផលខ្ពស់សំរាប់នាំចេញទៅលក់នៅក្រៅមូលដ្ឋាននៅឡើយ ។ ចំពោះផលគ្រាប់ស្វាយចន្ទីរគឺមានឈ្មួញប្រមូលទិញស្តុកទុកសំរាប់នាំចេញទៅលក់ដូរនៅក្រៅមូលដ្ឋាន ។
- ផលស្រូវក្នុងឃុំថ្មសមិនអាចផ្គង់ផ្គង់ស្បៀងក្នុងមូលដ្ឋានបានឡើយ ពីព្រោះប្រជាជនដែលធ្វើស្រែមានចំនួន ៥៨៣ គ្រួសារ ស្មើនឹង ៣២,០៧ % ។
    - ❖ តម្លៃស្រូវក្នុងមូលដ្ឋានជាមធ្យម ៦០០ រៀល ក្នុង ១ គីឡូក្រាម
    - ❖ តម្លៃស្រូវក្នុងមូលដ្ឋានខ្ពស់បំផុត ៧០០ រៀល ក្នុង ១ គីឡូក្រាម
    - ❖ តម្លៃស្រូវក្នុងមូលដ្ឋានទាបបំផុត ៥០០ រៀល ក្នុង ១ គីឡូក្រាម

**១.៤.៣. ឱកាស_ឧបស័គ្គ**

ធនធានជលផលគឺជាធនធានមួយដែលមានសក្តានុពលយ៉ាងខ្ពស់ក្រៅពីផ្តល់ជាអាហារ គឺជាប្រ ភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាជន និងសហគមន៏ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្នការប្រើប្រាស់ធនធានទាំងអស់ទទួលរងនូវការថយចុះយ៉ាងខ្លាំងដោយសារការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា ទូកឌុន ទូកអូស ឧបករណ៏ឆក់មងក្រឡាញឹក...។ល។

# ជំពូក ២

# ការវិភាគពីតំរូវការសំរាប់អនាគត ឧបស័គ្គ និងសក្តានុពល

## ២.១. តំបន់ស្រើប

ផ្នែកតាមការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានដែលជាផ្នែកសំខាន់សំរាប់ការរស់នៅរបស់មនុស្ស សត្វ ក្នុងការប្រាស្រ័យគ្នាទៅវិញទៅមក ដែលរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់គ្រប់គ្រង ថែរក្សា ការពារ និង ស្តារឡើង វិញ ។ នៅក្នុងឃុំថ្មសមានតំបន់អភិរក្សពូជមច្ឆា ១ កន្លែង ដែលបានបោះបង្គោលកំណត់ជាតំបន់មច្ឆាជាតិ ៣ង កូន និងដាំដើមកោងកាងឡើងវិញ ។ នៅឃុំថ្មសបានបង្កើតសហគមន៍នេសាទការពារឆ្នេរថ្មស ហើយសកម្មភាពសហគមន៍នេះ កំពុងបោះជំហានទៅមុខ ដើម្បីរក្សាធនធានមច្ឆាជាតិឱ្យបានគង់វង្ស ។

- ដីបំរុងបង្កើតសហគមន៏ព្រៃឈើមានទំហំ ១.៣៥៧ ហ.ត
- តំបន់ការពារឧទ្យានជាតិបុទុមសាគរមានទំហំ ២៣.២៩០,៨៦ ហ.ត
- ដីក្រុមហ៊ុនអភិវឌ្ឍន៏ទីក្រុង ( ក្រុមហ៊ុន Union Developments Group Co.Ltd ) ទំហំ ២,៦៥៤.៦៧ ហ.ត
- ដីសហគមន៏នេសាទ (ពុំទាន់មានការទទួលស្គាល់ជាផ្លូវការ)

## ២.២. ការប្រឈម/ឧបស័គ្គ

នៅក្នុងឃុំថ្មសកំណើនប្រជាជនចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលតំរូវការនៃការប្រើប្រាស់ដី និងធនធានធម្មជាតិក៏មានការកើនឡើងជាហេតុធ្វើឱ្យធនធានធម្មជាតិជួបប្រទះនូវការថយចុះ ដែលបណ្តាលឱ្យមានខ្យល់ព្យុះ ទឹកជំនន់ធ្វើឱ្យខូចខាតផ្ទះសំបែង ហេដ្ឋារចនាសម្ព័ន្ធ និង ដំណាំផ្សេងៗ ។ ទឹកជំនន់តែងតែកើតឡើងជាញឹកញាប់ ដែលបណ្តាលឱ្យខូចខាតដំណាំស្រូវ ភាគច្រើននៅក្នុងភូមិចំលងគោ ភូមិថ្មស និង ភូមិស្រែត្រាវ ។ ចំណែកឯគ្រោះរាំងស្ងួតក៏បញ្ហាមួយដែលប៉ះពាល់ដល់ការបង្កបង្កើនផលស្រូវចំការរបស់ប្រជាពលរដ្ឋម្តងម្កាលប៉ុណ្ណោះ ។

បញ្ហាសេដ្ឋកិច្ចនៅក្នុងឃុំថ្មសពីមួយឆ្នាំទៅមួយឆ្នាំមានការរីកចំរើនកើនឡើងជាលំដាប់ មានក្រុមហ៊ុនការ អភិវឌ្ឍន៏មួយចំនួនបានឈានចូលមកកាន់ឃុំថ្មស និងតំបន់ក្បែរខាងឃុំដែលបណ្តាលឱ្យប្រជាពលរដ្ឋធ្វើការរុករានទន្រ្ទានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិសំរាប់លក់ដូរ និងសំរាប់ដំណាំឈើហូបផ្លែ ដែលធ្វើឱ្យប៉ះពាល់ដល់ដីព្រៃដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិនាំឱ្យធនធានធម្មជាតិនៅក្នុងឃុំមានការបាត់បង់ ។




## ២.៣. កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំថ្មស

ក្នុងដំណើរការអភិវឌ្ឍន៏គោលដៅយុទ្ធសាស្ត្រ ឃុំបានធ្វើការលើកគម្រោងផែនការសំរាប់ពេលអនាគត ដែលក្នុងនោះបានកំណត់នូវផែនការជាអទិភាព ដើម្បីស្វែងរកការគាំទ្រពីក្រសួង មន្ទីរ អង្គការ និង សម្បុរសជននានា ក្នុងប្រើប្រាស់ថវិកាមូលនិធិឃុំ ឃុំមានគម្រោងអាទិភាពសំខាន់ៗ ចំនួន ១៥ ដូចក្នុងតារាងខាងក្រោម :

| ល.រ | គម្រោង ឬសកម្មភាព | លទ្ធផលគ្រោង | | ទីតាំងគំរោង ឬ សកម្មភាព | យោបល់របស់ ក្រុមប្រឹក្សា |
|---|---|---|---|---|---|
| | | ចំនួន | ឯកតា | | |
| 1 | លើកទំនប់ការពារទឹកប្រៃ | 6,628 | ម | ភូមិថ្មស ស្រែត្រាវ ស្រែថ្មី | |
| 2 | ធ្វើទ្វារបិទបើកទឹក | 3 | កន្លែង | ភូមិថ្មស ភូមិស្រែត្រាវ | |
| 3 | ធ្វើផ្លូវលំក្រាលគ្រួសក្រហម | 30 | គ.ម | គ្រប់ភូមិ | |
| 4 | ជួសជុល និង ពង្រីកផ្លូវ | 12 | គ.ម | គ្រប់ភូមិ | |
| 5 | ដាក់លូកាត់ផ្លូវ | 7 | កន្លែង | ភូមិថ្មស ភូមិចំលងគោ | |
| 6 | ធ្វើស្ពាន និង ជួសជុលស្ពាន | 7 | កន្លែង | ភូមិថ្មស,ស្រែត្រាវ,ស្រែថ្មី ភូមិចំការលើ,ចំលងគោ | |
| 7 | សង់សាលាបឋមសិក្សា | 2 | ខ្នង | ភូមិថ្មស,ភូមិចំការលើ | |
| 8 | សង់ផ្ទះសំណាក់អោយគ្រូមកពីឆ្ងាយស្នាក់នៅ | 5 | ខ្នង | ភូមិថ្មស,ស្រែត្រាវ,ស្រែថ្មី ភូមិចំការលើ,ចំលងគោ | |

| | | | | | |
|---|---|---|---|---|---|
| 9 | បង្កើតថ្នាក់មត្តេយ្យសាលា | 10 | ថ្នាក់ | ភូមិថ្នស,ស្រែថ្មី,ចំការលើ, ចំលងគោ | |
| 10 | សង់បង្គន់អនាម័យដល់គ្រួសារក្រីក្រ | 712 | គ្រួសារ | គ្រប់ភូមិ | |
| 11 | ជីកអណ្តូងស្នប់ | 51 | អណ្តូង | គ្រប់ភូមិ | |
| 12 | អភិរក្សព្រៃមាត់អូរ ព្រែក | 10 | កន្លែង | គ្រប់ភូមិ | |
| 13 | ជីកស្រះ ត្រពាំង | 10 | កន្លែង | គ្រប់ភូមិ | |
| 14 | កំណត់ព្រំប្រទល់ដីភូមិ | 5 | ភូមិ | គ្រប់ភូមិ | |
| 15 | បង្កើតសហគមន៍ព្រៃឈើប្រើប្រាស់ | 1 | សហគមន៍ | ភូមិស្រែថ្មី,ភូមិចំការលើ | |

## ២.៤. គំរូទការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១. អត្រាកំណើន

ស្ថានភាពអត្រាកំណើនប្រជាជននៅក្នុងឃុំថ្នស បើពិនិត្យទៅតាមបណ្តាឆ្នាំនីមួយៗឃើញថាមានការកើនឡើងគួរឱ្យកត់សំគាល់ ប្រសិនបើមើលទៅលើចំនួនគ្រួសារមានការកើនឡើងតែបើពិនិត្យទៅលើចំនួនប្រជាជនមានការកើនឡើងទៅតាមឆ្នាំនីមួយៗដូចជានៅឆ្នាំ ២០០៥ ចំនួនប្រជាជន ៩.៥៣៤ នាក់ ឆ្នាំ ២០០៦ ចំនួនប្រជាជន ៩.៤២៥ នាក់ ឆ្នាំ២០០៧ ចំនួនប្រជាជន ១០.០៦៧ នាក់ ឆ្នាំ២០០៨ ចំនួនប្រជាជន ១០.០៧៣ នាក់ កត្តានេះតាមការសាកសួរព័ត៌មានគឺបណ្តាលមកពីការចំណូលស្រុកក្នុងមូលដ្ឋាន ។ រីឯចំនួនគ្រួសារប្រជាពលរដ្ឋក្នុងឃុំមានកាកើនឡើងនៅតាមបណ្តាឆ្នាំ នីមួយៗ បើសិនជាពិនិត្យមើលទៅលើកុមារក៏មានការកើនឡើងដែរ ដែលអាចធ្វើឱ្យមានកង្វះខាតសាលារៀន ។ ចំពោះដីធ្លីនៅក្នុងឃុំក៏មានការខ្វះខាតក្នុងការពង្រីកលើវិស័យកសិកម្មដែរ ពីមួយឆ្នាំទៅមួយឆ្នាំប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ជាកត្តាមួយធ្វើឱ្យមានការកត់សំគាល់ទៅលើសក្តានុពល ដូចជាលទ្ធភាពនៃការពង្រីកអគារសិក្សា ការបង្កើន មុខរបរ ការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្ម ការរៀបចំប្រព័ន្ធស្រោចស្រព ការអភិរក្សនូវធនធានធម្មជាតិ និងកំណត់នៃការប្រើប្រាស់ធនធានឱ្យមាននិរន្តរភាពទើបធានាបាននូវអត្រាកំណើន ។

**តារាងការគណនាអត្រាកំណើនមធ្យម**

| ចំនួនគ្រួសារ ប្រ/ជ | 2005 | 2006 | 2007 | 2008 | កំនើនមធ្យម | កំនើន/ឆ្នាំ |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | 1,754 | 1,766 | 1,786 | 1,818 | - | - |
| អត្រាកំនើនគ្រួសារ | - | 0.7% | 1.1% | 1.8 % | 1.2% | 22គ្រួសារ |
| ចំនួនប្រជាជនសរុប | 9,534 | 9,425 | 10,067 | 10,073 | - | - |
| អត្រាកំនើន ប្រ/ជ | - | -1.1% | 6.8% | 0.1% | 1.9% | 191នាក់ |

នៅក្នុងអត្រានៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋនៅក្នុងអំឡុង ឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៨ ឃើញថា អាត្រាកំណើនមាន ១.២ % ផ្អែកតាមទិន្នន័យព័ត៌មាននៃផែនការអភិវឌ្ឍន៍ឃុំ និង តាមរយៈការគណនា រកអត្រាកំណើនរបស់ប្រជាពលរដ្ឋយើងឃើញថាចំនួនប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួលកើនឡើង កត្តានេះគឺអាស្រ័យដោយមូលហេតុដូចករណីខាងលើ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក៏អត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ១.៩ % ក្នុងមួយឆ្នាំគឺស្មើនឹង ១៩១ នាក់។

### ២.៤.១.២. ការធ្វើចំណោលប្រជាសាស្ត្រ

**តារាងការធ្វើចំណោលប្រជាសាស្ត្រ**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ 2012 | | ឆ្នាំ 2017 | | ឆ្នាំ 2022 | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម 05 ឆ្នាំ | 1,098 | 554 | 1,995 | 603 | 1,292 | 652 |
| អាយុ 05 ឆ្នាំ | 325 | 161 | 354 | 176 | 382 | 190 |
| អាយុ 6-11 ឆ្នាំ | 1,694 | 850 | 1,844 | 925 | 1,993 | 1,000 |
| អាយុពី 12-14 ឆ្នាំ | 938 | 469 | 1,021 | 510 | 1,103 | 552 |
| អាយុពី 15-17 ឆ្នាំ | 931 | 467 | 1,013 | 508 | 1,095 | 549 |
| អាយុពី 18-24 ឆ្នាំ | 1,191 | 602 | 1,296 | 656 | 1,401 | 709 |
| អាយុពី 25-60ឆ្នាំ | 4,010 | 2,023 | 4,063 | 2,201 | 4,716 | 2,379 |
| អាយុលើស 61 ឆ្នាំ | 650 | 337 | 707 | 366 | 764 | 396 |
| ចំនួន ប្រ/ជ សរុប | **10,837** | 5,463 | **12,293** | 5,945 | **12,746** | 6,427 |
| ចំនួនគ្រួសារសរុប | **1,956** | | **2,128** | | **2,301** | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំថ្នល់ បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំម្តង សំរាប់រយៈពេល១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋមធ្យម ១.៩% ក្នុងនោះស្មើនឹង ១៩១ នាក់ ក្នុងមួយឆ្នាំ ហើយនឹង ១.២% ស្មើនឹង២២គ្រួសារក្នុងមួយឆ្នាំ បើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៍ដែរ ព្រោះអត្រាកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំថ្នល់ គឺវាពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ធនធានដែលមាននៅក្នុងឃុំ ពិសេសបរិមាណដីសំរាប់ធ្វើកសិកម្ម និង បច្ចេកទេសក្នុងការបង្កើនផលិតផលដើម្បីបំរើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំ ។



### ២.៤.២. តំរូវការសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋានទីប្រជុំជន និង ជនបទ គឺដីលំនៅដ្ឋានភូមិសំដៅទៅដល់ដីដែលប្រើប្រាស់សំរាប់សង់ផ្ទះ និងសំរាប់សួនដំណាំគ្រួសារ (លំអិតសូមមើលឧបសម្ព័ន្ធ១ ) សំរាប់ឆ្នាំ ២០០៨ ដីលំនៅដ្ឋានទីប្រជុំជន និងជនបទ មានទំហំសរុបចំនួន ៤២៥,៤២ ហិកតា សំរាប់ប្រជាជនប្រមាណ ១.៨១៨គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺមាន ២.៣០០ ម៉ែត្រការ៉េ ស្មើ ០,២៣ ហិកតា។ ដែលទំហំនេះអាចជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន តំរូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

- កំណើនគ្រួសារ ២០២២ ស្មើ៤៨៣ គ្រួសារ x ០,២៣ ហ.ត = **១១១.០៩ ហ.ត**

សរុប = **១១១.០៩ ហ.ត**

### ២.៤.៣. តំរូវការដីកសិកម្ម

តំរូវការដីកសិកម្មគឺរួមមានដីសំរាប់ស្រែវស្សា ដីដំណាំចំការ ដីចំការឈើហូបផ្លែ សំរាប់ឆ្នាំគោល ២០០៨ មាន ទំហំ ៣.០៧៤,៤៨ ហិកតា សំរាប់ប្រជាជនសរុបចំនួន ១.៨១៨ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ១,៦៩ ហិកតា ។ តែប្រជាជននៅក្នុងឃុំថ្មសមានប្រមាណ ៤៩,១៧% ស្មើនឹង ៨៩៤គ្រួសារ មានមុខរបរសំខាន់ គឺនេសាទ សមុទ្រ ព្រោះភូមិទាំង៥របស់ឃុំថ្មសមានទីតាំងជាប់ឆ្នេរសមុទ្រ ដូច្នេះមានតែប្រជាជន ៤៦,២៦% ស្មើនឹង ៨៤១គ្រួសារ តែប៉ុណ្ណោះដែលមានមុខរបរពឹងផ្អែកជាចំបងលើវិស័យកសិកម្ម ដែលអាចមានដីប្រកបរបរកសិកម្មជាមធ្យមគឺ ៣,៦៥ ហ.ត ដែលជាទំហំមួយធំល្មមសំរាប់មួយគ្រួសារ ។

ដោយយោងទៅតាមអត្រាចំនួនគ្រួសរដែលធ្វើកសិកម្មចំបង ពិសេសដំណាំស្រូវក្នុងឆ្នាំគោលឆ្នាំ២០០៨ ដែលមានអត្រា ៤៦.២៦ភាគរយ ស្មើនឹង ៨៤១គ្រួសារ ដូច្នេះកំនើនគ្រួសារដល់ឆ្នាំ ២០២២ ដែលមានចំនួន ២៣០១គ្រួសារ

អាចមានអត្រាគ្រួសារអ្នកធ្វើស្រែចំការចំនួន ៥៨.៥៥ភាគរយ គឺស្មើនឹង ១,០៦៤គ្រួសារ ដូច្នេះបើប្រៀបធៀបទៅនឹង ឆ្នាំគោល ២០០៨ មានអត្រាកំនើន ១២.២៩ភាគរយ ស្មើនឹង ២២៣ គ្រួសារ ដែលត្រូវការដីកសិកម្មសំរាប់ប្រកប របរចិញ្ចឹមជីវិត ដូច្នេះតំរូវការដីកសិកម្មសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | | |
|---|---|---|---|
| - ចំនួនគ្រួសារមានដីតិចជាង ១ ហិកតា | ៣១៤គ្រួសារ x ៣ ហ.ត | = | ៩៤២ ហ.ត |
| - កំណើនគ្រួសារ ២០២២ | ២២៣គ្រួសារ x ៣,៦៥ ហ.ត | = | ៨១៣,៩៥ ហ.ត |
| | **សរុប** | **=** | **១,៧៥៥,៩៥ ហ.ត** |

ខាងលើនេះជាការវិភាគទៅលើទំហំដី តែបើយើងវិភាគទៅតាមចំនួនប្រជាជនផ្ទៃដីដំណាំស្រូវគឺយើងឃើញថា ទិន្នផលស្រូវជាមធ្យមមាន ៣តោន ក្នុងមួយហិកតា ( *ប្រភពទិន្នន័យពីសៀវភៅស្ថានភាពឃុំ*) ហើយប្រជាជនម្នាក់ៗ ត្រូវការស្រូវ ២៣០ គក្រ ក្នុង១ឆ្នាំ តាមស្ថិតិ ឃុំ ផ្ទៃដីស្រែប្រមាណ ៥៥៦,៩៧ ហិកតា ទទួលផលស្រូវ ១.៦៧០,៩១ តោន ។ តំរូវការស្រូវជាក់ស្តែងសំរាប់ ប្រជាជនឆ្នាំ គោល ២០០៨ ចំនួន ១០.០៧៣ នាក់ គឺ ២,៣១៦,៧៩ តោន ហើយបើយោងតាមតំរូវការនេះនៅខ្វះចំនួន ៦៤៥,៨៨ តោន ស្មើនឹង ២៧,៨៨% ត្រូវនឹងដីស្រែទំហំ ២១៥ ហ.ត។ ឯកំណើនប្រជាជនរហូតដល់ឆ្នាំ ២០២២ គឺមានរហូតដល់ ២.៦៧៣ នាក់ ត្រូវការស្រូវបន្ថែម ៦១៤,៧៩តោន ស្មើនឹង ផ្ទៃដីស្រែ ២០៥ ហ.ត ។ ដូច្នេះដើម្បី បំពេញតំរូវការស្បៀងឱ្យបានគ្រប់គ្រាន់សំរាប់ប្រជាជនកើនឡើងនៅឆ្នាំ ២០២២ ឃុំត្រូវការដីសំរាប់ធ្វើស្រែ ទំហំ ៩.៧៦,៩៧ហ.ត បើប្រៀបធៀបជាមួយដីស្រែបច្ចុប្បន្នគឺត្រូវការដីស្រែបន្ថែមចំនួន ៤២០ហ.ត តែប៉ុណ្ណោះ ។ ដូចនេះដើម្បីធានាអោយបាននូវសន្តិសុខស្បៀងនៅក្នុងឃុំ និងអាចឈានទៅដល់ការនាំចេញ ផងនោះ ឃុំត្រូវការពង្រីកដីស្រែថ្មី ចំនួន **៦៧៣ហ.ត** បន្ថែមទៀត ដោយអនុវត្តកម្មវិធី ប.វ.ស ។

### ២.៤.៤. តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ឃុំថ្មសជាឃុំមួយដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ ជាតំបន់អភិរក្សធនធានព្រៃឈើ ព្រៃកោងកាង ព្រៃភ្នំ មាត់ព្រែក អូរ ព្រមទាំងវាលស្មៅ ដីដែលបានកំណត់ជាតំបន់រសើប និង ដីផ្សេងៗដែលជាតំរូវការសំរាប់ប្រើប្រាស់ ស្ថិតនៅក្នុងតំបន់អភិរក្សក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ធនធានជលផលគ្រប់គ្រងដោយរដ្ឋបាលជលផល ។ ដើម្បីធានានូវធនធានធម្មជាតិឱ្យមាននិរន្តរភាពយូរអង្វែង អាជ្ញាធរមូលដ្ឋានមានផែនការទប់ស្កាត់ការកាប់ព្រៃ និងព្រៃ កោងកាង និងព្រៃផ្សេងៗទៀតដើម្បីរានយកដីធ្វើកម្មសិទ្ធិ ហើយមានគំរោងដាំព្រៃកោងកាងឡើងវិញនៅតំបន់ ដែលមាន ការរិចរិល និង ។

### ២.៤.៥. តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាចគឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជន ដោយមិន បានញែកចេញដោយឡែកនោះទេ ហើយមានការគិតគូរជារួមលើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គម ដែលមានទ្រង់ទ្រាយ ធំទើបមានការគិតគូរដោយឡែក ។ និយាយរួមដីសំរាប់តំរូវការហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ ជារួមជាមួយនឹងដី ត្រៀមបំរុងសំរាប់ពង្រីកភូមិ និង ទីប្រជុំជន ។

តាមការប៉ាន់ប្រមាណជាសរុបដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម គឺមានតំរូវការបន្ថែមចំនួន ១៤.៤៣០,១១ម៉ែត្រ ចំពោះផ្លូវ ទំនប់ធំៗ គឺមិនមានការគិតគូរជាផ្ទៃដីទេគឺគិតតែប្រវែង ហើយនឹងបង្ហាញក្នុងផែនទីដោយឡែក ។

**តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័នសង្គម និងសេវាកម្មទូទៅ :**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន 15 ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 2បន្ទប់ | 07បន្ទប់ | 05 បន្ទប់ |
| សាលាបឋមសិក្សា | 07 ខ្នង(28បន្ទប់) | 09 ខ្នង(38បន្ទប់) | 02ខ្នង |
| សាលាអនុវិទ្យាល័យ | 01 ខ្នង (5បន្ទប់) | 02ខ្នង | 01ខ្នង |
| សាលាវិទ្យាល័យ | 0 | 01ខ្នង(5បន្ទប់) | 01ខ្នង |
| មណ្ឌលសុខភាព | 01 | 00 | 00 |
| ប៉ុស្តិ៍សុខភាព | 0 | 03 កន្លែង | 03 |
| បង្កើតអគារបណ្តុះបណ្តាលវិជ្ជាជីវៈ | 0 | 01 ខ្នង | 01 |
| ស្រះទឹកស្អាត | 02 | 04 | 02 |
| អណ្តូងទឹកស្អាត( លូ ឬ ស្នប់) | 10 | 14 | 4 |
| បង្កើតទីតាំងចាក់សំរាម | 01កន្លែង | 05 កន្លែង | 04 កន្លែង |
| បង្កើតទីស្នាក់ការភូមិ | 0 | 05 កន្លែង | 05 |

សូមបញ្ជាក់ថា: អគារសំរាប់ថ្នាក់មត្តេយ្យសិក្សានៅមិនទាន់មាននៅឡើយ ប៉ុន្តែបច្ចុប្បន្នសិស្សថ្នាក់មត្តេយ្យត្រូវបានខ្ចីថ្នាក់រៀនពីសាលាបឋមសិក្សាចំនួន០២បន្ទប់ ។

### ២.៤.៥.១. តំរូវការដីសាលារៀន

ផ្ទៃដី និងទីតាំងសាលារៀននៅក្នុងឃុំថ្នសត្រូវបានកំណត់ និងទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានច្បាស់លាស់ ដោយទីកន្លែងមួយចំនួនស្ថិតនៅតាមភូមិដូចជា ភូមិថ្នស ចំលងគោ ស្រែថ្មី និងភូមិចំការលើ ដោយឡែកសំរាប់តំរូវការថ្ងៃ អនាគតគឺត្រូវពង្រីកអគារបន្ថែដោយសាងសង់នៅក្នុងទីតាំងចាស់ដែលមានស្រាប់ ចំណែកនៅភូមិចំការលើវិញពុំមានសាលាអនុវិទ្យាល័យទេ ។ ហើយទីតាំងភូមិចំការលើនៅឆ្ងាយពីសាលាអនុវិទ្យាល័យថ្នស (ភូមិថ្នស) សិស្សដែលរៀនចប់កំរិតបឋមពិបាកក្នុងការធ្វើដំណើរទៅរៀននៅអនុវិទ្យាថ្នស ប៉ុន្តែសំរាប់ថ្ងៃអនាគតត្រូវសាងសង់អគារបន្ថែម ហើយសាលានៅភូមិផ្សេងៗទៀតមិនចាំបាច់បន្ថែមកំរិតសិក្សាទេ ព្រោះមានទីតាំងនៅជិតអនុវិទ្យាល័យ និងវិទ្យាល័យថ្នសស្រាប់ ។

- ថ្នាក់មត្តេយ្យនៅឆ្នាំ ២០១២ សាងសង់ ០១ អគារមាន ០៥ បន្ទប់ សំរាប់សិស្សឆ្នាំ ២០១២ ចំនួន ០១ បន្ទប់ (៥ ឆ្នាំទី ១) ឆ្នាំ ២០១៧ ចំនួន ០២ បន្ទប់ (៥ ឆ្នាំទី ២) ឆ្នាំ ២០២២ ចំនួន ០២ បន្ទប់ (៥ ឆ្នាំទី ៣) ។
- សាលាបឋមសិក្សាឆ្នាំ ២០១២ មាន ០២ អគារចំនួន ១១ បន្ទប់ សាងសង់នៅលើទីតាំងដីសាលាចាស់ (៥ ឆ្នាំទី ១)នៅភូមិថ្នស ០១ អាគារ នៅភូមិចំការលើ ០១ អាគារ ។

- ឆ្នាំ ២០១៧ សាលាបឋមសិក្សាមាន ០២ អគារ ចំនួន ០៨ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី២ ។
- ឆ្នាំ ២០២២ សាលាបឋមសិក្សាមាន ០២ អគារ ចំនួន ១២ បន្ទប់ សាងសង់នៅ ៥ឆ្នាំ ទី៣ ។
- សាលាអនុវិទ្យាល័យឆ្នាំ ២០១២ មាន ០១ អគារ ចំនួន ០៤ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី ១ ។
- សាលាអនុវិទ្យាល័យឆ្នាំ ២០១៧ មាន ០១ អគារ ចំនួន ០៦ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី ២ ។
- សាលាអនុវិទ្យាល័យឆ្នាំ ២០២២ មាន ០១ អគារ ចំនួន ០៥ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី ៣ ។
- សាលាវិទ្យាល័យឆ្នាំ ២០១២ មាន ០២ អគារ ចំនួន ១០ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី ១ នៅឆ្នាំ ២០១៧សិស្សវិទ្យាល័យដែលកើនចំនួន ០១ ថ្នាក់ ត្រូវរៀនក្នុងសាលាដែលសាងសង់នៅឆ្នាំ ២០១២ ។
- សាលាវិទ្យាល័យឆ្នាំ ២០២២ មាន ០២ អគារ ចំនួន ១០ បន្ទប់ សាងសង់នៅ ៥ឆ្នាំទី ៣ ។

សាលាខាងលើនេះសាងសង់នៅទីតាំងដីសាលាចាស់នៅភូមិថ្នស ។

**តារាងកំណើនកុមារ ថ្នាក់រៀន និងសាលារៀននៅឆ្នាំ ២០១២-២០២២**

| ប្រភេទសាលា | នៅឆ្នាំ 2012 | | | នៅឆ្នាំ 2017 | | | នៅឆ្នាំ 2022 | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | 325 | 0 | 1 | 354 | 0 | 2 | 382 | 0 | 2 |
| ថ្នាក់បឋមសិក្សា | 1,694 | 2 | 11 | 1,844 | 2 | 8 | 1,993 | 2 | 12 |
| ថ្នាក់អនុវិទ្យាល័យ | 938 | 1 | 4 | 1,021 | 1 | 6 | 1,103 | 1 | 5 |
| ថ្នាក់វិទ្យាល័យ | 931 | 2 | 9 | 1,013 | 0 | 1 | 1,095 | 2 | 10 |



### ២.៤.៥.២. សេវាកម្មសុខភាព និង ការផ្គត់ផ្គង់ទឹកស្អាត

#### ក-សេវាកម្មសុខភាព

ស្ថិតក្នុងតំណាក់កាលនេះឃុំថ្មសក៏ពុំមានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលដល់ការទ្រទ្រង់សុខភាពរបស់ប្រជាពលរដ្ឋបន្ថែមទៅលើមណ្ឌលសុខភាពនៅឡើយ ។ ចំងាយមធ្យមពីភូមិទៅមណ្ឌលសុខភាពឃុំចំពោះ ភូមិស្រែត្រាវ មាន ២ គីឡូម៉ែត្រ ដោយឡែកភូមិចំការលើមានចំងាយផ្លូវជាមធ្យម ២១ ទៅ ២៨ គីឡូម៉ែត្រ ។ ផ្នែកទៅតាមភូមិសាស្រ្តនៃឃុំថ្មសដែលមានប្រជាជននៅក្នុងភូមិដាច់ពីគ្នា និង មានចំងាយផ្លូវពីមណ្ឌលសុខភាពឃុំបណ្តាលឱ្យមានការលំបាកក្នុងការទៅមក ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់នៅឡើយ ។

ការខ្វះខាតលើមណ្ឌលសុខភាពគឺជាកត្តាសំខាន់ បើពិនិត្យទៅលើប៉ុស្តិ៍សុខភាពនៅតាមភូមិនីមួយៗមិនទាន់ មាននៅឡើយទេ។

#### ខ- ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំថ្មសមាន ០២ភូមិ គឺ ភូមិចំឡងគោ និងភូមិថ្មស ។ ភូមិចំលងគោបានរៀបចំប្រពន្ធ័ទឹកស្អាតពីសំណាក់ឯកជនជាម្ចាស់ កម្មសិទ្ធិផ្ទាល់ដែលមានទីតាំងស្ថិត នៅខាងក្រោយ វត្តចំលងគោ ដើម្បីយក មកប្រើប្រាស់នៅក្នុងភូមិចំឡងគោ។ ឯក្នុង ភូមិថ្មស វិញប្រជាជនបានប្រើប្រាស់ទឹកស្អាត ពីអាងស្តុកទឹក ដែលជាដីសាធារណៈរបស់រដ្ឋដែលអភិវឌ្ឍន៏ដោយឯកជន ហើយប្រជាជនមួយចំនួនក៏ប្រើប្រាស់ស្រះទឹកក្នុងវត្តអង្គសិលាមុន្នី (ហៅវត្តថ្មស) ដែរ។ ប៉ុន្តែបញ្ហាចំបង នៅ ឡើយចំពោះភូមិ ស្រែថ្មី ស្រែត្រាវ និងភូមិចំការលើ ពុំមានទឹកស្អាតប្រើប្រាស់នៅឡើយទេ គឺប្រើប្រាស់តែ អណ្តូងទឹក នៅក្នុងភូមិ ដែលបានសាងសង់ពីមុននោះ មួយចំនួនត្រូវបានខូចខាត ដូចនេះជាជំហានដំបូងនៃផែនការអភិវឌ្ឍន៍ឃុំ ត្រូវស្តារ និង ជួសជុល នូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅខាងមុខឃុំ បានលើកគម្រោងផែនការ ក្នុងការជីកស្រះស្តុកទឹកស្អាត ជីកអណ្តូងលូ និង អណ្តូងស្នប់ទឹកស្អាត ។

### ២.៤.៥.៣. ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៏ទៅលើវិស័យវប្បធមិនិងសាសនា ជាកត្តាមួយសំខាន់ ដើម្បីចូលរួមចំណែក ជំរុញឱ្យមានសន្ទុះដល់ការអប់រំ ផ្នែកព្រះពុទ្ធសាសនា ។ នៅតាមវត្តអារាមនីមួយៗមានគំរូរូបភាពជាច្រើន ជារបៀបសាសនា ព្រះពុទ្ធ និងវប្បធមិ ដែលអប់រំដល់មនុស្សគ្រប់ៗ ជំនាន់អោយចេះស្គាល់វប្បធមិ សាសនា របស់ខ្លួន និងស្គាល់គុណទោស ក្នុងគោលបំណងអោយមនុស្ស គ្រប់រូបចេះស្រឡាញ់គ្នា គ្មានអំពើហឹង្សាក្នុងគ្រួសារ សង្គម និង ដើម្បីឱ្យមនុស្ស ដើរតាមច្បាប់របស់រាជរដ្ឋាភិបាលដែលបានកំណត់ ។

ជាអាទិភាពក្នុងឃុំថ្មស បច្ចុប្បន្នកន្លែងសំរាប់គោរពបូជា ប្រពៃណី សាសនា នៅថ្ងៃអនាគតមិនទាន់មានតំរូវការបន្ថែមនៅឡើយ។



**តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | 1 | 2 | 1 |
| ទីកន្លែងសក្ការៈបូជា | 0 | 1 | 1 |
| វត្តអារាម | 2 | 3 | 1 |
| ផ្សេងៗ | | | |

### ២.៤.៥.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមសភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមាននៅឃុំថ្មស ឃើញថា ផ្លូវមួយចំនួនត្រូវធ្វើការកែលំអ និង ដាក់លូដូចជា ផ្លូវគ្រួសក្រហមដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវខូច និង ប្រព័ន្ធលូមួយចំនួនត្រូវបានទឹកហូរដាច់ និង ផ្លូវលំដីស មួយចំនួនត្រូវពង្រីកបន្ថែម ឃុំកំពុងលើគំរោងផែនការជួសជុលកែលំអឱ្យផ្លូវ និង លូ ស្ពាន មួយចំនួនតាមស្តង់ដាជាបន្តបន្ទាប់ ។ ក្រៅពីនោះឃុំក៏បានគ្រោង ធ្វើផែនការអភិវឌ្ឍន៍រយៈពេល ១៥ ឆ្នាំ ខាងមុខ ដូចជាកសាងទំនប់ទឹកប្រៃនៅភូមិស្រែត្រាវ ស្រែថ្មី និងភូមិថ្មសមានប្រវែង ៦៦២៨,០៨ ម៉ែត្រ ដើម្បីពង្រីកដីព្រែកបន្ថែម ជូនប្រជាជន មួយចំនួនឱ្យមានជីវភាពធូធារ នៅក្នុងឃុំថ្មសទាំងមូល ។

- ស្ថានភាពលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឃុំថ្មសភាគច្រើននៅតាមឆ្នេរសមុទ្រ ពួកគាត់ងាយស្រួលក្នុងការចត ទូក ចេញចូលនៅពេលនេសាទ ម្យ៉ាងទៀតឃុំនេះមានផ្លូវគ្រួសក្រហមដែលចូលភូមិជាលក្ខណៈងាយស្រួលក្នុងការដឹក ជញ្ជូនផលិតផលស្បៀងចេញចូលបាន ។

- ឃុំថ្មសមិនទាន់មានអាងស្តុកទឹកសំរាប់ស្រោចស្រព្វ និង ប្រឡាយមេទូទាំងឃុំនៅឡើយ ហើយប្រជាជន ធ្វើស្រែពឹងផ្អែកទៅលើទឹកភ្លៀង ទាំងស្រុង ។




**តារាងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ឆ្នាំនេះ (២០០៨) | ១៥ ឆ្នាំខាងមុខ | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលបេតុង | 0.00 m | 1,159.00m | 1,159.00m |
| ផ្លូវក្រាលគ្រួសក្រហម | 30,161.00m | 79,301.00m | 49,140.00m |
| ប្រវែងផ្លូវក្រាលដីស | 16,253.00 m | 16,253.00 m | 0.00 |
| ផ្លូវរទេះ ឬថ្មើជើង | 74,300.00m | 74,300.00m | 0.00 |
| ប្រឡាយមេ | 0,00 | 7,759.00m | 7,759.00m |
| ប្រឡាយរង | 0,00 | 2,122.00m | 2,122.00m |
| ស្រះទឹក | 01 | 11 | 10 |
| ចំនួនស្ពានថ្ម និង បេតុង | 05 | 12 | 07 |
| ចំនួនស្ពានឈើ | 1.00 | 00 | 00 |
| ចំនួនទ្វារទឹក | 0.00 | 02 | 02 |
| ទំនប់ការពារទឹកប្រៃ | 00.00m | 3,500.00m | 3,500.00m |
| ចំនួនលូកាត់ផ្លូវ | 05 | 12 | 07 |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីអនាគត

## ៣.១. ស្ថានភាពដី សក្តានុពលដី និងតំរូវការដី

### ៣.១.១. ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំថ្មសធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលដល់ការប្រើប្រាស់ និងអភិរក្ស អភិវឌ្ឍន៍ទៅលើធនធានទាំងនោះឱ្យមាននិរន្តភាពដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដីនៃនាទីព្រៃលិចទឹក គឺជា បរិស្ថានធម្មជាតិដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានរស់នៅ នៃធនធានជលផលនៅក្នុងតំបន់នោះ ។ នៅក្នុងក្របខណ្ឌនៃការរស់នៅ របស់ពពួកភាវរស់គឺជាបណ្តាញនៃប្រព័ន្ធអេកូឡូស៊ី នៅក្នុងមជ្ឈដ្ឋាននាទីព្រៃលិចទឹក ដែលបានផ្តល់នូវសារប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាអាទិ៍ដូចជា : ព្រៃលិចទឹកផ្តល់នូវទីជំរកដល់ពពួកភាវរស់ និងសត្វផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹក ដូចជាពពួកត្រី អណ្តើក គន្ធាយ ពស់ ស្វា អន្សង ត្រកួត និង សត្វស្លាប ជាច្រើនប្រភេទ ។ល។ ទាំងនោះគឺជាសក្តានុពលមួយដែលផ្តល់នូវសារប្រយោជន៍ដល់ប្រជាជនរស់នៅក្នុង មូលដ្ឋាន សំរាប់ការដកយកផលពីព្រៃលិចទឹក ដូចជាវល្លិ៍ ឱសថបូរាណសំរាប់ព្យាបាល និង ជារបាំងការពារខ្យល់ ។

សក្តានុពលធនធានព្រៃឈើ គឺជាតំបន់អភិរក្សគ្រប់គ្រងដោយក្រសួងបរិស្ថាន ជាតំបន់ឧទ្យានជាតិបូទុមសាគរក្នុងតំបន់អភិរក្សនេះសំបូទៅដោយធនធានធម្មជាតិច្រើនប្រភេទ សំរាប់អោយប្រជាពលរដ្ឋក្នុងតំបន់នេះទាញយកអនុផលព្រៃឈើដូចជា : ជ័រឈើ វល្លិ៍ ឬស សំរាប់ធ្វើថ្នាំបូរាណ និង ផលអនុផលជាច្រើនទៀត ។ល។

សក្តានុពលសមុទ្រ ព្រែក តូចធំ គឺសំបូរទៅដោយមច្ឆាជាតិជាច្រើនប្រភេទសំរាប់អោយប្រជាពលរដ្ឋតំបន់នេះប្រកបមុខរបរចិញ្ចឹមជីវិត ។

### ៣.១.២. តំរូវការដីតាមប្រភេទ

អត្រាកំណើនប្រជាពលរដ្ឋគឺជាការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ទៅលើធនធានធម្មជាតិ ដូច្នេះយើងត្រូវតែធ្វើការពិចារណាធនធានដែលមាននៅក្នុងឃុំ។ ផ្អែកទៅតាមអត្រាកំណើនខាងលើឃុំ ឃុំបានរៀបចំនូវគម្រោងផែនការទៅលើតម្រូវការពង្រីកដីភូមិដោយបានកំណត់លើផ្ទៃដីស្ថិតនៅតាមសងខាងបណ្តោយផ្លូវ សំរាប់តាំងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋមួយផ្នែកដីចំការ និងដីស្រែអចិន្ត្រៃតាមភូមិសាស្ត្រជាក់ស្តែងរបស់ឃុំ។ ជាមួយគ្នានេះដែរឃុំគ្រោងផែនការអភិវឌ្ឍន៍ និងពង្រីកដីបន្ថែមសំរាប់អនាគតដោយស្របច្បាប់ ជាពិសេសដីសំរាប់ធ្វើកសិកម្ម និង សហគមន៍ព្រៃឈើតំបន់ការពារ កម្មជាតិ ។

- ដីចំការដំណាំរយៈពេលខ្លី ប្រភេទដីនេះត្រូវពង្រីកតាមរយៈការពង្រីកដីភូមិព្រោះដំណាំរយៈពេលខ្លីនេះភាគច្រើនប្រជាជនដាំជាប់ជាមួយដីលំនៅដ្ឋាន ។
- ចំពោះដីសំរាប់ដាំដំណាំឈើហូបផ្លែជាដីទួលដែលមានដំណាំអចិន្ត្រៃយ៍ និង ដីចំការចាស់មួយចំនួនតាមគោលការណ៍របស់ឃុំ ។

- ក្រៅពីនេះឃុំថ្មសនៅមានព្រៃលិចទឹក និង ព្រៃកោងកាងមួយផ្នែកធំដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការការពារអភិរក្សនៅលើធនធានធម្មជាតិដែលមានស្រាប់ សំរាប់ទ្រទ្រង់ផ្នែកវិស័យជលផល ក៏ដូចជាការពារធនធានធម្មជាតិព្រមទាំងលើកគម្រោងផែនការដាំដើមកោងកាងបន្ថែម ដើម្បីរួមចំណែកក្នុងការអភិរក្សមាននិរន្តរភាពនៅក្នុងឃុំ។

- ផ្ទៃដីសហគមន៍មកនេសាទដែលគ្រប់គ្រងដោយស្ថាប័នជលផលដល់សហគមន៍នេសាទនេះ និង ការប្រើប្រាស់ប្រកបដោយនិរន្តភាព ។ ដូច្នេះប្រភេទដី និង ផ្ទៃទឹកស្ថិតនៅក្នុងក្របខណ្ឌជាដីសាធារណៈរបស់រដ្ឋ មិនអាចយកដីនេះប្រើប្រាស់សំរាប់ប្រយោជន៍ឯកជនឡើយ ។ ជាមួយគ្នានេះដែរឃុំក៏មានការអភិរក្ស ព្រៃលិចទឹកដោយសហការណ៍ជាមួយឧទ្យាជាតិដែលមានស្រាប់ ដើម្បីធានាលើកកំពស់សេដ្ឋកិច្ចពេលអនាគតក្នុងឃុំ ។

**តារាងតំរូវការនៃការប្រើប្រាស់ដីអនាគត**

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ ហ.ត | ក្រឡាផ្ទៃ ១៥ ឆ្នាំ ហ.ត | បំរែបំរួល ហ.ត |
|---|---|---|---|
| ដីលំនៅដ្ឋានទីប្រជុំជន | 15.49 | 15.49 | 0.00 |
| ដីវាលកប់ខ្មោច | 0.00 | 5.00 | 5.00 |
| ដីស្រែវស្សា | 556.96 | 1,229.96 | 673.00 |
| ដីលំនៅដ្ឋានភូមិ | 409.92 | 521.01 | 111.09 |
| ដីចំការដំណាំឈើហូបផ្លែ | 396.17 | 396.17 | 0.00 |
| ដីព្រៃលិចទឹក | 104.57 | 104.57 | 0.00 |
| ដីចំការដំណាំ | 35.99 | 35.99 | 0.00 |
| អូរ ឬ ស្ទឹង | 91.11 | 91.11 | 0.00 |
| តំបន់អភិរក្សមច្ឆាជាតិ | 0.00 | 904.46 | 904.46 |
| ដីព្រៃកោងកាង | 369 | 864 | 495.00 |
| ដីបំរុងបង្កើតសហគមន៍ព្រៃឈើ | 0.00 | 1,357.00 | 1,357.00 |

## ៣.២. ការបែងចែកដីតាមតំរូវការប្រើប្រាស់

### ៣.២.១. ការវិភាគអន្តរអំពើ

ការគ្រប់គ្រង និងបែងចែកសំរាប់ការប្រើប្រាស់ ជាកត្តាដែលធ្វើឱ្យមានការផ្តល់នូវផលប្រយោជន៍ និងមាននិរន្តភាព ហើយនឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលក្នុងនោះមានដូចជា :

- ការប្រែប្រួលពីដីវាលស្មៅទៅជាដីស្រែសំរាប់បង្កបង្កើនផលនេះជាកាពង្រីកលើវិស័យកសិកម្មជាកត្តាមួយជួយស្តារផ្នែកបង្កបង្កើនផលស្បៀងក្នុងមូលដ្ឋាន។ នៅក្នុងបរិបទនេះការប្រែប្រួលប្រភេទដីប្រសិនបើដីវាលស្មៅបោះបង់ចោលឬដី ស្រែចាស់ៗមិនធ្វើនោះជាលក្ខណៈងាយស្រួលដល់ការពង្រីកដីសំរាប់ធ្វើស្រែបន្ថែម ។ ប៉ុន្តែដីវាល

ស្មៅមួយចំនួន ដែលធ្វើអោយ ប៉ះពាល់ដល់ធនធានធម្មជាតិព្រមទាំងបាត់បង់ ឬមានការបំរែបំរួលក្នុងការរកប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

- ការធ្វើចំការដំណាំឈើហូបផ្លែ ដើម្បីជួយទ្រទ្រង់ជីវភាពប្រជាពលរដ្ឋមួយផ្នែក ប៉ុន្តែសព្វថ្ងៃប្រជាជនដែលមានដីចំការដំណាំមួយចំនួនត្រូវបានបោះបង់ចោលបណ្តាលមកពីកត្តាជាច្រើនដូចជា :
- គ្មានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ខ្វះបច្ចេកទេសកសិកម្ម ភ្លើងឆេះព្រៃ ។ល។
- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និងចរាចរគ្រប់ប្រភេទចូលរួមក្នុងការកាត់បន្ថយការ ចំណាយទៅលើការងារដឹកជញ្ជូន ការអភិវឌ្ឍន៍នេះថ្វីត្បិតតែមានការប៉ះពាល់ខ្លះៗក៏ដោយ ប៉ុន្តែអាចផ្តល់នូវផលប្រយោជន៍ដល់ ប្រជាជនប្រើប្រាស់របស់ប្រជាជនទូទៅ ។
- ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើទីតាំង និង ដីសំរាប់សាងសង់អាគារសិក្សាបន្ថែមគឺជាការចាំបាច់ បំផុតសំរាប់បង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន បច្ចុប្បន្ននៅឃុំថ្មសដីអាគារសិក្សាទាំងបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ នៅមានទីតាំងទូលាយសំរាប់សង់សាលាបន្ថែមបានទៅថ្ងៃអនាគត ។ បច្ចុប្បន្នទោះជានៅឃុំនេះ មានសាលាបឋមសិក្សា អនុវិទ្យាល័យ នៅតាមភូមិក៏ដោយ បញ្ហាចោតគឺមិនមានគ្រូបង្រៀនគ្រប់គ្រាន់នៅឡើយ ។

### ៣.២.២. ផែនទីប្រើប្រាស់ដីពេលអនាគត

***ផែនទីពង្រាងប្រើប្រាស់ដីពេលអនាគត ឃុំថ្មសឆ្នាំ ២០០៩-២០២២***



### ៣.២.៣. ការបរិយាយការប្រើប្រាស់តាមក្បាលដី

- ការប្រើប្រាស់ដីនៅក្នុងឃុំថ្មស អាជ្ញាធរមូលដ្ឋានមិនទាន់មានការបែងចែកក្បាលដីជូនប្រជាជននៅឡើយ ប៉ុន្តែប្រជាជនក្នុងឃុំនេះមានការចាប់ដីតាំងលំនៅជាដុំៗ នៅតាមដងផ្លូវធំ តូចដែលមានស្រាប់ និង ប្រជាជនមួយចំនួនតាំងលំនៅដ្ឋានតាមមាត់ឆ្នេរ និង លើទឹកសមុទ្រ ។

- ការប្រើប្រាស់ដីលំនៅដ្ឋាន ឬ ដីភូមិជាដីដែលផ្តល់នៅសក្តានុពលនៅលើការសាងសង់លំនៅដ្ឋានរបស់ប្រជាជនដោយមានការដាំដំណាំរួមផ្សំជាមួយដូចជា : ដូង ស្វាយ ខ្នុរ ត្របែក ចេក ល្ហុង ...។ល។ និងកន្លែងមួយចំនួនទៀតដាំដំណាំរយៈពេលខ្លីដូចជា ជំឡូង ពោត ត្រឡាច ល្ពៅ ត្រកួន .....។ល។ ចំពោះប្រជាជនដែលគ្មានដីគោកសំរាប់ដាំដំណាំរួមផ្សំ ឬ បន្លែត្រូវបានទិញឯផ្សារ ។

- នៅក្នុងឃុំថ្មសក៏នៅមានការប្រែប្រួលដីជាបន្តបន្ទាប់ពីដី ស្រែ ចំការ មកជាដីលំនៅដ្ឋាន តាមរយៈការរីករាលដាលគ្រួសារថ្មីរបស់ប្រជាជនដែលមានការបែងចែកដីទុកឱ្យកូន ។ រីឯការរីករាលដាលគ្រួសារថ្មីនេះ ភាគច្រើនកើតនៅតាមបណ្តោយផ្លូវ ឬ នៅជិតទីប្រជុំជន ។

- ការប្រើប្រាស់ដីសំរាប់ធ្វើស្រែនៅឃុំថ្មសមិនត្រូវបានបែងចែកតាមប្រភេទស្រូវ ឬ ប្រភេទដីឡើយ ដោយប្រជាជននៅឃុំនេះធ្វើស្រែបានតែមួយរដូវវស្សា ហើយពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ការធ្វើស្រែរបស់ប្រជាជននៅឃុំនេះ មិនទាន់មានបច្ចេកទេសផ្នែកកសិកម្មឡើយ ដោយធ្វើស្រែបែបបុរាណ និង ប្រជាជនមួយផ្នែកទៀតធ្វើស្រែប្រភេទស្រូវស្រាលលើដីមាត់សមុទ្រទឹកប្រៃហូរចូលដោយមានការលំបាកបំផុតក្នុងការប្រមូលផល ។

- ពាក់ព័ន្ធដីស្រែ និង ការប្រើប្រាស់ខាងលើ អាជ្ញាធរឃុំថ្មស ពុំទាន់មានគោលការណ៍ អភិវឌ្ឍន៍ កែប្រែដីស្រែ និង បង្កើតបច្ចេកទេសកសិកម្មនៅឡើយ ។

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ជាដីស្ថិតក្នុងដែនឧទ្យានជាតិបុទុមសាគរ) ដូច្នេះឃុំមានផែនការ សហការជាមួយឧទ្យានជាតិក្នុងការការពារអភិរក្សទៅលើធនធានទាំងនេះ ដើម្បីផ្តល់ផលប្រយោជន៍ក្នុងការបង្កើតរកប្រាក់ចំណូលរបស់ប្រជាជនតាមរយៈការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព ព្រមទាំងធ្វើផែនការដាំកូនកោងកាងបន្ថែមដាក់ចូលក្នុងផែនការ សមាហរណកម្មប្រចាំឆ្នាំងផងដែរ ។

- ដោយឡែកប្រជាជនមួយចំនួនបានសង់ លំនៅដ្ឋាននៅលើទឹកសមុទ្រ ហើយត្រូវបានទាញយកផលប្រយោជន៍ពីក្នុងទឹកសមុទ្រ យកមកចិញ្ចឹមជីវិតតាមរយៈការនេសាទដូចជា: បង្គារ ត្រី ក្តាម ខ្យង .ល.។ អាជ្ញាធរឃុំក៏ចូលរួមចំណែកបង្កើតសហគមន៍នេសាទ និង រក្សាតំបន់អភិរក្ស ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានផលប៉ះពាល់ផ្នែកបរិស្ថានមួយផ្នែកនៅថ្ងៃអនាគត ។ ដូច្នេះនៅពេលអនាគតប្រសិនបើ រាជរដ្ឋាភិបាលមានគោការណ៍សមស្របណាមួយឱ្យប្រជាជនទាំងនោះត្រឡប់មករស់នៅតំបន់ដីគោកជាការល្អប្រសើរបំផុត ។

- ការប្រើប្រាស់ដីសំរាប់សាងសង់ផ្លូវថ្នល់ ក៏នៅមានបញ្ហាមួយចំនួន ប៉ុន្តែអាចដោះស្រាយបានព្រោះ ផ្លូវដែលកើតឡើង គឺជាការចាប់ផ្តើមពីប្រជាពលរដ្ឋផ្ទាល់ ហើយឃុំលើកគំរោងអភិវឌ្ឍន៍នេះទៅតាមការស្នើសុំពីសំណាក់ប្រជាពលរដ្ឋ។ បច្ចុប្បន្នការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចាស់ និងផ្លូវថ្នល់ថ្មី អាជ្ញាធរដោះស្រាយបានតាមរយៈការសម្រប

សម្រួលពីប្រជាពលរដ្ឋ ។

### ៣.២.៣.១. ដីលំនៅដ្ឋាន (បញ្ញត្តិ គោលការណ៍ និងការប្រើប្រាស់ដី)

ដីលំនៅដ្ឋានដែលឃុំបានគ្រោងនេះជាទូទៅជាដីលំនៅដ្ឋានភូមិ និងភាគច្រើនស្ថិតនៅតាមបណ្តោយផ្លូវចំនួន ០៦កន្លែង ដែលមាន លេខកូដនៅលើផែនទីប្រើប្រាស់ដីអនាគត F1200-01,02,03,04,05,06 យោងទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋ ៤៨៣ គ្រួសារសំរាប់រយៈពេល ១៥ ឆ្នាំ ប៉ុន្តែដោយយោងទៅតាមអនុក្រិតលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ចតម្រូវអោយ ក្នុងមួយគ្រួសារទទួលបានដីបានយ៉ាងច្រើន ០.២៥ ហ.ត តែប៉ុណ្ណោះ ដូច្នេះតាមការគិតគូររបស់ឃុំទៅលើការកំណត់ ផ្ទៃដីលំនៅដ្ឋានភូមិ ក្នុង មួយ គ្រួសារ ០,២៣ ហ.ត ដូចនេះផ្ទៃដីសរុបដែលឃុំគ្រោងមានទំហំ ១១១.០៩ ហ.ត ។

**<u>បញ្ញត្តិនៃការប្រើប្រាស់ដីសំរាប់សង់លំនៅដ្ឋានថ្មីគឺ :</u>**

នៅក្នុងការពង្រីកដីលំនៅដ្ឋាន ឃុំមានគោលការណ៍រៀបចំដីភូមិដោយមានការកំណត់ និងជំរុញឱ្យមានដីភូមិដែលមានសណ្តាប់ធ្នាប់សាធារណៈល្អ ហើយក្នុងនោះត្រូវបានអនុវត្ត :

- រាល់ដីភូមិដែលត្រូវរៀបចំថ្មីត្រូវបានកំណត់ទុកដីចំណីផ្លូវស្របច្បាប់កំណត់ទុក
- ការសាងសង់លំនៅដ្ឋានក្នុងភូមិត្រូវបានអនុវត្តទៅតាមច្បាប់អនុញ្ញាត
- ជំរៅដីសំរាប់សង់លំនៅដ្ឋានមិនអាចលើសពី ១០០ ម៉ែត្រ ពីអ័ក្សផ្លូវ
- មិនត្រូវសាងសង់លំនៅដ្ឋានលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត
- រាល់ដីភូមិដែលកើតថ្មីត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ព័ន្ធ ហើយត្រូវបានបោះ បង្គោលរបងកំណត់ព្រំច្បាស់លាស់ ។
- ជំរុញ និង ផ្សព្វផ្សាយឱ្យមានការចូលរួមបង្កើននូវផលិតផលតាមរយៈការរៀបចំជាសួនដំណាំក្នុងដីភូមិដូចជាសួនបន្លែ និងដំណាំរួមផ្សំរយៈពេលខ្លី និងវែងដែលជាកត្តាជួយឱ្យក្នុងភូមិមានសភាពបៃតងដោយមានលទ្ធភាពបង្កើន ប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពនេះ ។
- ចំពោះប្រជាពលរដ្ឋដែលរស់នៅលើដីសាធារណៈ (ដីមាត់ព្រែក មាត់សមុទ្រ ) បច្ចុប្បន្នអ្នកដែលរស់នៅចាស់ មានការលំបាកក្នុងការផ្លាស់ប្តូរ ហើយជាបណ្តើរៗឃុំនឹងព្យាយាមធ្វើការដោះដូរ និងរៀបចំឱ្យបានត្រឹមត្រូវ ប៉ុន្តែជា គោលការណ៍ឃុំធ្វើការហាមឃាត់ដាច់ខាតការសាងសង់លំនៅដ្ឋានថ្មី ។

### ៣.២.៣.២. ដីស្រែ

ការប្រើប្រាស់ដីសំរាប់ដីស្រែនៅក្នុងឃុំថ្មសធ្វើស្រែតែមួយរដូវប៉ុណ្ណោះគឺរដូវវស្សា ដោយមានការប្រែប្រួលនៃកំណើនប្រជាពលរដ្ឋ ឃុំបានធ្វើការគិតគូរលើការពង្រីកដីស្រែដែលមានស្រាប់ ហើយជាដីស្រែដែលបានបោះបង់ចោលពីមុននោះត្រូវបានធ្វើការរៀបចំកែលំអឡើងវិញដោយអនុលោមទៅតាមលក្ខណៈបច្ចេកទេសប្រពលវប្បកម្មដំណាំ ស្រូវ ដល់ប្រជាពលរដ្ឋដើម្បីផ្តល់ឱកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ។

ចំពោះដីស្រែដែលទុកចោលទំនេរនេះគឺជាដីដែលស្ថិតនៅចំណុចភូមិស្រែត្រាវ ស្រែថ្មី និង ថ្នស ចំការលើ បច្ចុប្បន្នឃុំបានគ្រោងទុកដីទាំងបីភូមិនេះជាដីដែលបានទុកចោលពីមុនមក ហើយដែលមានលេខកូចក្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត គឺ F2110-01,02,03,04,05,06 ។

**➢ គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម**

នៅក្នុងកិច្ចអភិវឌ្ឍន៍សំរាប់ពេលអនាគត ឃុំមានគោលការណ៍ក្នុងការរៀបចំនូវការបង្កើនផលិតកម្មដំណាំ ស្រូវ ដែលក្នុងនោះត្រូវអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួន ដែលអាចជួយដល់ការបង្កើនផលិតភាពកសិកម្មគឺៈ

- ☞ លើកកំពស់ការប្រើប្រាស់ជីរធម្មជាតិ និងជីរកំប៉ុស្តិ៍
- ☞ កាត់បន្ថយការប្រើប្រាស់ជីរគីមី
- ☞ កាត់បន្ថយការប្រើប្រាស់ថ្នាំពុល ជំរុញការអនុវត្តន៏កម្មវិធី IPM
- ☞ រៀបចំប្រពលវប្បកម្មដំណាំស្រូវ (បរស)
- ☞ អភិវឌ្ឍន៍លើការស្តារ និងសាងសង់ប្រព័ន្ធស្រោចស្រព ដើម្បីប្រើប្រាស់ឱ្យអស់នូវផ្ទៃដីស្រែដែលមាន។
- ☞ ជំរុញការធ្វើស្រែបង្កើនរដូវ
- ☞ បង្កើនការដាំដុះដំណាំរយៈពេលខ្លីទៅលើដីស្រែ ដែលមានលទ្ធភាពក្នុងការស្រោចស្រពដើម្បីឱ្យការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធិភាព និងមានតម្លាភាព ឃុំបានកំណត់ដូចខាងក្រោម :
  - ហាមដាច់ខាតការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ
  - ហាមដាច់ខាតការវាតដីស្រែចូលដីបឹង ត្រពាំង ឬ ប្រឡាយ
  - ហាមដាច់ខាតការកាប់រានចូលដីនាទីព្រៃលិចទឹកដើម្បីធ្វើស្រែ
  - រាល់ដីស្រែ ត្រូវមានភ្លឺសំរាប់សំគាល់ព្រំប្រទល់ច្បាស់លាស់

### ៣.២.៣.៣. ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព

ការប្រើប្រាស់ដីផ្ទៃទឹកនានានៅក្នុងឃុំ ជាកត្តាចម្បងសំរាប់ប្រជាជនក្នុងមូលដ្ឋានដើម្បីបំរើផលប្រយោជន៍ឱ្យវិស័យកសិកម្ម និងការប្រើប្រាស់ទូទៅផ្នែកតាមធនធានទឹកដែលមានក្នុងឃុំរួមមាន ឃុំអាចមានលទ្ធភាពក្នុងការដកយកមកប្រើបានតែប្រភេទ ទឹកអូរ ត្រពាំង បឹង អណ្តូង ស្រះ តែប៉ុណ្ណោះ ដោយឡែកចំពោះប្រព័ន្ធប្រឡាយបច្ចុប្បន្នពុំអាចមានលទ្ធភាពក្នុងការប្រើប្រាស់បានឡើយ (ប្រឡាយរីង រាក់ )នៅក្នុងផែនការប្រើប្រាស់ដីអនាគត់សំរាប់រយៈពេល ១៥ឆ្នាំខាងមុខឃុំបានគ្រោងក្នុងការសាងសង់ទំនប់ និងប្រឡាយទឹកមួយចំនួនដើម្បីធានាបាននូវការបង្កបង្កើនផលដំណាំស្រូវដែលនៅលើផែនទីប្រើប្រាស់ដីអនាគតមានបង្ហាញនូវលេខកូដដូចខាងក្រោមៈ

- ☞ ទំនប់ការពារទឹកប្រៃ FDN64-01
- ☞ ប្រឡាយមេ FDN57-01,02,03,04,05
- ☞ និងប្រឡាយរង FDN56-01,02

### ប្រព័ន្ធស្រោចស្រព

ការប្រែប្រួលពីដីស្រែមកជាដីប្រព័ន្ធប្រឡាយ ឬ ដីប្រឡាយមេចាស់មកជាប្រឡាយថ្មីជាបញ្ហាចោទ ព្រោះថាមានការលំបាកសំរាប់ការដោះស្រាយនៅបញ្ហាប្រឈម ដោយបច្ចុប្បន្នមានបញ្ហាមួយចំនួននឹងត្រូវកើតមានឡើងក្នុងពេលប្រឡាយចាប់ផ្តើមដំណើរការសាងសង់ និងស្តារដូចជាការរំលោភយកដីប្រឡាយធ្វើស្រែ ហើយបញ្ហាមួយផ្សេងទៀតក្នុងករណីមានការសាងសង់ប្រឡាយថ្មី បញ្ហានឹងកើតឡើងដោយសារការមិនយល់ពីសារៈប្រយោជន៍ក្នុងការប្រើប្រាស់ប្រឡាយ ដូច្នេះបញ្ហានៃការប៉ះពាល់ដីស្រែធ្វើឱ្យឃុំប្រឈមមុខក្នុងការដោះស្រាយ ។

**បញ្ញត្តិ និង គោលការណ៍នៃការកសាង និងស្តារប្រឡាយ**

- នៅក្នុងលក្ខខណ្ឌនៃការសាងសង់ និងស្តារប្រឡាយត្រូវមានការកំណត់ឱ្យបានច្បាស់ទៅលើការដោះស្រាយបញ្ហាទើបដំណើរការប្រព្រឹត្តិទៅទទួលជោគជ័យ ។
- រៀបចំគណៈកម្មការចុះដោះស្រាយ អនុវត្ត និងថែទាំ
- ការសាងសង់ប្រឡាយថ្មីត្រូវអនុវត្តទៅតាមផែនការដែលបានគ្រោងទុក( ទំហំប្រឡាយ៤ ម. ជំរៅ ២,៥០ ម.) ដោយមានភ្លឺប្រឡាយសងខាង ២ ម៉ែត្រ ដោយចោតពីមាត់ប្រឡាយ ១,៥០ ម៉ែត្រ ។
- ការស្តារប្រឡាយចាស់ត្រូវអនុវត្តសមស្របទៅតាមទំហំប្រឡាយចាស់
- ត្រូវធ្វើការដោះស្រាយឱ្យបានរួចរាល់នូវការរំលោភយកដីប្រឡាយចាស់ និងកែសំរួលទៅតាមស្ថានភាពជាក់ ស្តែង និង សមស្របតាមគោលការណ៍ច្បាប់ ។

### ការប្រើប្រាស់ទឹក

ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅលើផ្ទៃទឹក ព្រែក និងសមុទ្រ ត្រូវបានប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋានដូចជា ការប្រកបរបរនេសាទនៅលើដែននេសាទដោយមានការការពារ ថែរក្សា និង អភិរក្ស ។ ប៉ុន្តែកត្តានេះមានការពាក់ព័ន្ធទៅនឹងផលប៉ះពាល់បរិស្ថាន ដូចច្នេះនៅពេលអនាគតប្រសិនបើរដ្ឋាភិបាលមានគោលការណ៍ឱ្យប្រជាជនដែលរស់នៅតំបន់ព្រែក និងសមុទ្រត្រូវផ្លាស់ប្តូរលំនៅដ្ឋានមករស់នៅផ្ទែកខាងលើគោកវិញ ឃុំនឹងធ្វើការចូលរួមរកដំណោះស្រាយឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ការរៀបចំស្តារត្រពាំង ប្រឡាយ ស្រះ អណ្តូង បឹង ឡើងវិញគឺជាកត្តាចម្បងសំរាប់ការផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍន៏លើប្រព័ន្ធស្រោចស្រព ព្រោះវាជាប្រភពទឹកមួយដ៏សំខាន់សំរាប់ឃុំថ្នសទាំងមូល ។

**បញ្ញត្តិនៃការស្តារប្រឡាយ ត្រពាំង ស្រះ អណ្តូង**

- ស្តារប្រឡាយ ត្រពាំង ស្រះ អណ្តូង ដោយអនុវត្តទៅតាមទំហំ និង ស្ថានភាពដែលមានស្រាប់
- រៀបចំច្រាំងប្រឡាយ ត្រពាំង ស្រះ ដែលបានខូចខាត បាក់ច្រាំង ឱ្យមានជើងទេរដោយមានការដាំស្មៅ ឬរុក្ខជាតិការពារការហូរច្រោះ ។
- បង្កើតសហគមន៏ប្រើប្រាស់ និងថែទាំទឹកត្រពាំង ស្រះ អណ្តូង

- ចាត់វិធានការចំពោះអ្នកមកតាំងទីលំនៅថ្មីលើដីមាត់ព្រែក និង សមុទ្រ (ដីសាធារណៈរបស់រដ្ឋ)
- ដាក់ចេញជាគោលការណ៍សំរាប់ការការពារ និងថែរក្សាអនាម័យចំពោះអ្នកមានលំនៅដ្ឋានជាប់ត្រពាំង ស្រះ អណ្តូង និង អ្នកប្រើប្រាស់ទឹក ។

### ៣.២.៣.៤. ការសាងសង់ស្ពានឆ្លងព្រែក និងទ្វារទឹក

នៅក្នុងការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធ ឃុំក៏បានចាប់អារម្មណ៍លើការសាងសង់ស្ពានឆ្លងព្រែក ឬ អូរ ដែលក្នុងនោះត្រូវបានគ្រោងការសាងសង់ស្ពានបេតុងនៅចំណុចភូមិស្រែថ្មី និង ភូមិចំការលើ មានចំនួន ០៧ កន្លែង និងទ្វារទឹកចំនន្ទន០២កន្លែង ក្នុងនោះត្រូវបានដំណើរការតាមទីតាំង និងស្ថានភាពដូចខាងក្រោមៈ

#### ❖ទីតាំងនៃការសាងសង់ស្ពានបេតុង

ការសាងសង់ស្ពានឆ្លងព្រែក ឬ អូរ គឺជាការចាំបាច់ ហើយឃុំបានធ្វើការកំណត់លើការសាងសង់ស្ពានបេតុង ចំនួន ០៧ កន្លែង នៅភូមិស្រែថ្មី និង ភូមិចំការលើ ដែលមានលេខកូដនៅលើផែនទីប្រើប្រាស់ដីអនាគត FDN71-1,02,03,04,05,06,07 ។

#### ❖ទីតាំងនៃការសាងសង់ទ្វារទឹក

ជាមួយនឹងគំរោងផែនការក្នុងការសាងសង់ទ្វារទឹកគឺឃុំបានផ្តោតជាសំខាន់ទៅតាមតំរូវការនៃការសាងសង់ប្រព័ន្ធប្រឡាយទឹកដែលឃុំបានលើកគំរោងក្នុងនេះឃុំបានសិក្សា និងកំណត់បាននូវចំនួនទ្វារទឹកដែលត្រូវសាងសង់ក្នុងពេល អនាគតចំនួន ០៣ កន្លែងថ្មីទៀត ។ ទ្វារទឹកថ្មី ០២កន្លែង ស្ថិតនៅភូមិថ្មស និង ភូមិស្រែត្រាវ ដែលមានលេខកូដ FDN70-01,02 ។

#### បញ្ញត្តិ និង គោលការណ៍នៃការសាងសង់ស្ពាន និង ទ្វារទឹក

- ការសាងសង់ស្ពានត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែងលើកំពស់ទឹកខ្ពស់បំផុត
- ការជ្រើសរើសទីតាំងត្រូវអនុលោមទៅតាមស្ថានភាពនៃចរន្តទឹកហូរ និងស្ថានភាពព្រែក ចៀសវាងកន្លែងដែល មិនសមស្របដែលធ្វើឱ្យចាល់ និងបង្វែរចរន្តទឹកហូរបណ្តាលឱ្យបាក់ច្រាំងព្រែក ។
- ការសាងសង់ត្រូវអនុវត្តទៅតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ ហើយត្រូវគិតគូរ និងចៀសវាងនូវកត្តាដែលធ្វើឱ្យ ប៉ះពាល់ដល់បរិស្ថាន ។
- នៅក្នុងស្ថានភាពនៃការសាងសង់ទ្វារទឹកត្រូវធ្វើការសិក្សាស្រាវជ្រាវ និង ធ្វើការវាយតម្លៃ ដោយស៊ីជម្រៅទៅលើចរាចរនៃប្រភពធនធានជលផល ។

### ៣.២.៣.៥. ការប្រើប្រាស់ផ្លូវថ្នល់

ការប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរប៉ុន្តែអាចដោះស្រាយបានព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាពលរដ្ឋផ្ទាល់ដែលជាអ្នកធ្វើឱ្យកើតមានផ្លូវជាដំបូង ហើយឃុំក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងឃុំ គឺអនុវត្តទៅ

លើផ្លូវចាស់មានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។ ចំពោះផ្លូវដែលឃុំមានគំរោងសាងសង់នោះមានចំនួន ០៩ខ្សែរ និងមានលេខកូដនៅលើផែនទី FRD3-01, 02, 03, 04, 05, 06, 07, 08, 09 ហើយការសាងសង់នេះត្រូវធ្វើទៅតាមផែនការរយៈពេល ១៥ឆ្នាំដែលឃុំបានកំណត់។

### ៦ទីតាំងនៃការសាងសង់ផ្លូវក្រាលគ្រួសក្រហម

ជាមួយនឹងគំរោងផែនការក្នុងការសាងសង់ទ្វារទឹកគឺឃុំបានផ្តោតជាសំខាន់ទៅតាមតំរូវការនៃការសាងសង់ប្រព័ន្ធប្រឡាយទឹកដែលឃុំបានលើកគំរោង ក្នុងនេះផ្លូវក្រាលគ្រួសក្រហមនឹងត្រូវសាងសង់ និងជួសជុលមាន ចំនួន ០៩ខ្សែរ ដែលមានលេខកូដនៅលើផែនទី FRD3-01, 02, 03, 04, 05, 06, 07, 08, 09 និងមានប្រវែងសរុបចំនួន ៤៩.១៤៣.00 ម៉ែត្រ ហើយការសាងសង់នេះត្រូវ ធ្វើទៅតាមផែនការរយៈពេល ១៥ឆ្នាំដែលឃុំបានកំណត់ទៅតាមដំណាក់កាល ៥ឆ្នាំម្តង។

**ផ្លូវគំរោងអនាគតៈ**

១-ចេញពីចំណុចមាត់សមុទ្រត្រង់ដើមត្នោតពីរដើមខាងក្រោមវត្តចំលងគោជាប់ព្រំប្រទល់ក្រុមហ៊ុន Union Deverlopment Group Co Ltd. ឆ្ពោះទៅ ចំណុចគ្រួសក្រហម និងផ្លូវលំចាស់ឆ្ពោះទៅភូមិចំការលើដែលមានប្រវែង ១៧.៧៥៣ ម មានលេខកូដ (FRD3-09) សំរាប់ ៥ឆ្នាំទី៣។

២-ផ្លូវមួយខ្សែចេញពីពកសេមាន់ទៅជាប់ផ្លូវគ្រួសក្រហមផ្លូវចូលភូមិថ្មសត្រង់ចំណុចព្រៃករាក់ប្រវែង ៩.៧៤0 ម មានលេខកូដ (FRD3-07) សំរាប់ ៥ឆ្នាំទី៣។

៣-ផ្លូវចេញពីមាត់សមុទ្រត្រង់ចំណុចពយអំពិល (ឡទឹកត្រី) ឆ្ពោះទៅចំនុចផ្លូវចូលភូមិស្រែថ្មី ប្រវែង ៦.១៤0 ម មានលេខកូដ (FRD3-06) សំរាប់ ៥ឆ្នាំទី៣ ។

៤-ផ្លូវចូលភូមិស្រែថ្មីទៅភ្ជាប់ជាមួយផ្លូវ លេខកូដ FRD3-07 ត្រង់ចំណុចព្រៃកធំប្រវែង ២.៧៣៤ ម មានលេខកូដ (FRD3-08) សំរាប់ ៥ឆ្នាំទី២ ។

៥-ផ្លូវភ្ជាប់ពីចំណុចចុងទំបន់ភូមិស្រែថ្មីឡើងមកផ្លូវគ្រួសក្រហមពីផ្លូវជាតិលេខ ៤៨ មានប្រវែង ៩៩៩ម មាន លេខកូដ(FRD3-04) សំរាប់ ៥ឆ្នាំទី១ ។

៦-ផ្លូវភ្ជាប់ពីទំនប់ទៅភូមិស្រែថ្មី មានប្រវែង ១.៨៩២ ម មានលេខកូដ (FRD3-05) សំរាប់ ៥ឆ្នាំទី៣។

៧-ផ្លូវភ្ជាប់ពីចំណុចផ្លូវចាស់របស់ជប៉ុនឡើងទៅរកផ្លូវគ្រួសក្រហមដែលភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុច ព្រៃករាក់ មានប្រវែង ៧,៦៧៧ ម មានលេខកូដ (FRD3-01) សំរាប់ ៥ឆ្នាំទី២។

៨-ផ្លូវភ្ជាប់ពីភូមិថ្មស ទៅឡទឹកត្រី មានប្រវែង ១,៦៩៧ ម មានលេខកូដ (FRD3-02) សំរាប់ ៥ឆ្នាំទី១ ។

៩-ផ្លូវភ្ជាប់ពីខាងជើងភូមិស្រែថ្មី ឡើងមកផ្លូវគ្រួសក្រហមដែលតភ្ជាប់ពីផ្លូវជាតិលេខ ៤៨ មានប្រវែង ៥0៨ ម មានលេខកូដ (FRD3-03) សំរាប់ ៥ឆ្នាំទី១ ។

នៅថ្ងៃអនាគត ប្រជាពលរដ្ឋដែលកើនអាចសង់លំនៅដ្ឋាន តាមសងខាងផ្លូវគ្រោះក្រហមមួយខ្សែ ដែលចេញ

ពីផ្លូវ៤៨ ទៅឃុំថ្មស និងចំនុចមួយទៀតគឺៈភូមិ ចំលងគោ ចំនុចតំបន់គ្រោះក្រហម បច្ចុប្បន្នមានប្រជាជនរស់នៅ ជាង ៣០ គ្រួសារ ។

**៥ទីតាំងនៃការដាក់លូកាត់ផ្លូវ**

តំរូវការក្នុងពេលអនាគតតំរូវឱ្យមានការសាងសង់លូឆ្លងផ្លូវ និងលូរំដោះទឹកចំនួន ០៧ កន្លែង ដែលក្នុងនោះមានទីតាំងនៅភូមិថ្មស និង ចំលងគោ គ្រោងសាងសង់នៅ ០៥ ឆ្នាំទី១ ។

### បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់

ក្នុងលក្ខណៈបច្ចេកទេសនៃការសាងសង់ផ្លូវត្រូវបានកំណត់សំរាប់ផ្លូវដូចខាងក្រោម :

- ផ្លូវក្រាលគ្រួសក្រហមក្នុងក្របខ័ណ្ឌមូលដ្ឋានឃុំត្រូវទុកដីចំណីផ្លូវ ១៥ ម៉ែត្រសងខាង
- ការកំណត់លើការប្រើប្រាស់ផ្លូវត្រូវអនុលោមទៅតាមច្បាប់
- បង្កើតសហគមន៍ថែទាំផ្លូវដោយមានចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ហាមការដឹកជញ្ជូនលើសទម្ងន់
- ហាមការយកគោ ក្របី ជ្រូក ចងលើផ្លូវ
- រៀបចំផ្លាកសញ្ញាចរាចរតាមបណ្តោយផ្លូវ

### ៣.២.៣.៦. ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ និង ទីតាំងសាលាថ្មី

នៅក្នុងឃុំថ្មសដោយតំរូវការអគារសិក្សាសំរាប់សាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ និង វិទ្យាល័យត្រូវបានគ្រោងបង្កើតសាលា និងសាងសង់អគារបន្ថែមដែលក្នុងនោះ :

- បង្កើតសាលាមត្តេយ្យចំនួន ០១ អគារមាន ០៥ បន្ទប់ដែលស្ថិតនៅភូមិថ្មសក្នុងទីតាំងសាលាបឋមសិក្សាចាស់ការសាងសង់នឹងត្រូវអនុវត្តនៅ ០៥ ឆ្នាំ ទី១ ។
- សាលាបឋមសិក្សានៅឆ្នាំ ២០១២ ត្រូវសាងសង់ ០២ អគារ មាន ១១ បន្ទប់ ការសាងសង់នឹងត្រូវអនុវត្តនៅ ០៥ ឆ្នាំ ទី១ ស្ថិតនៅភូមិថ្មស ០១ អគារ និង ភូមិចំការលើ ០១ អគារ ។
- សាលាបឋមសិក្សានៅឆ្នាំ ២០១៧ ត្រូវសាងសង់ ០២ អគារ មាន ០៨ បន្ទប់ ស្ថិតនៅទីតាំងចាស់ ការសាងសង់ នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ។
- សាលាបឋមសិក្សានៅឆ្នាំ ២០២២ ត្រូវសាងសង់ ០២ អគារ មាន ១២ បន្ទប់ ស្ថិតនៅទីតាំងចាស់ ការសាងសង់ នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី ៣ ។
- សាលាអនុវិទ្យាល័យនៅឆ្នាំ ២០១២ត្រូវសាងសង់ ចំនួន ០១ អគារ មាន ០៥ បន្ទប់ ស្ថិតនៅទីតាំងសាលាចាស់ ភូមិថ្មស ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី១ ។
- សាលាអនុវិទ្យាល័យនៅឆ្នាំ ២០១៧ត្រូវសាងសង់ ចំនួន ០១ អគារ មាន ០៦ បន្ទប់ ស្ថិតនៅទីតាំងសាលាចាស់ ភូមិថ្មស ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ។

- សាលាអនុវិទ្យាល័យនៅឆ្នាំ ២០២២ត្រូវសាងសង់ ចំនួន ០១ អគារ មាន ០៥ បន្ទប់ ស្ថិតនៅទីតាំងសាលាចាស់ ភូមិថ្នស ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី៣ ។
- សាលាវិទ្យាល័យនៅឆ្នាំ ២០១២ ត្រូវសាងសង់ចំនួន ០២ អគារ មាន ១០ បន្ទប់ ស្ថិតនៅទីតាំងសាលា ចាស់ ភូមិថ្នស ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី១ ។
- សាលាវិទ្យាល័យនៅឆ្នាំ ២០២២ ត្រូវសាងសង់ចំនួន ០២ អគារ មាន ១០ បន្ទប់ ស្ថិតនៅទីតាំងសាលា ចាស់ ភូមិថ្នស ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី៣ ។

### ៣.២.៣.៧. ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន

ការប្រើប្រាស់ដីព្រៃឧទ្យានជាតិ ព្រៃដុះតាមមាត់ទឹក និងព្រៃកោងកាង (ដីសារណៈរបស់រដ្ឋ) គឺត្រូវទាមទារឱ្យមានការថែរក្សាឱ្យបានគង់វង្ស ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍន៍ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ធនធានប្រកបដោយ និរន្តរភាព ។

នៅក្នុងដំណើរការនៃការការពារធនធានធម្មជាតិ និង បរិស្ថាននៅក្នុងឃុំថ្នសត្រូវបានអនុវត្ត និងកំណត់ទៅតាមក្របខ័ណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័ននីមួយៗ ដូចជាដែននេសាទរបស់ សហគមន៍នេសាទទឹកសាប និង ទឹកប្រៃ (ពុំទាន់មានការទទួលស្គាល់ជាផ្លូវការនៅឡើយទេ) ឧទ្យានជាតិបូទុមសាគរមានផ្ទៃក្រឡា ២៣,៧១២.៦០ ហិចតា ។

នៅក្នុងសហគមន៍នីមួយត្រូវបានរៀបចំជាកន្លែងអភិរក្សព្រៃលិចទឹក ដែលជាជំរកដ៏ប្រសើរសំរាប់ធនធាន ជលផលដូច្នេះដើម្បីធានានូវសុវត្ថិភាពស្បៀង និង និរន្តរភាពធនធានធម្មជាតិក្នុងតំបន់ ឃុំបានយកចិត្តទុកដាក់ចូលរួម ការពារ និង ថែរក្សាឱ្យមានស្ថិរភាពយូរអង្វែង ដោយបង្កើតអោយមានគំរោងមួយចំនួនដូចជា :

- ☞ ដាំព្រៃកោងកាងឡើងវិញនៅតំបន់ដែលមានការបាត់បង់ព្រៃកោងកាង និងតំបន់ដែលរិចរិល ចំនួន ០៨ កន្លែងមានទំហំសរុប ៤៩៥ ហ.ត ដែលមាន លេខកូដនៅលើផែនទីប្រើប្រាស់ដីអនាគត F3100-01, 02, 03, 04, 05, 06, 07, 08 ។
- ☞ តំបន់អភិរក្សធានមច្ឆាជាតិ មួយកន្លែងដែលស្ថិតនៅក្នុងដែនសហគមន៍នេសាទ មានទំហំ ៩០៤ ហ.ត ដែលមានលេខកូដនៅលើផែនទីប្រើប្រាស់ដីអនាគត F7400-01 ។
- ☞ សហគមន៍ព្រៃឈើមួយកន្លែងដែលបច្ចុប្បន្នឋិតនៅក្រោមការគ្រប់គ្រងរបស់ឧទ្យានជាតិបូទុមសាគរ ហើយសហគមន៍ព្រៃឈើមួយនេះមានទំហំ ១,៣៥៧ ហ.ត ដែលមានលេខកូដនៅលើផែនទីប្រើប្រាស់ដីអនាគត F3710-01 ។

### បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ធនធាន

នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានរបស់សហគមន៍នេសាទត្រូវបានរៀបចំគ្រប់គ្រង និង ប្រើប្រាស់ទៅលើព្រៃលិចទឹកដែលក្នុងនោះត្រូវបានបែងចែក :

- កំណត់ការដកយកផល និង អនុផលព្រៃលិចទឹក ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងសហគមន៍ នេសាទ ។
- ហាមការចាប់សត្វព្រៃគ្រប់ប្រភេទនៅក្នុងកន្លែងព្រៃអភិរក្ស ។
- ហាមការចាប់សត្វដែលច្បាប់ជលផលបានកំណត់ ។
- ហាមកាប់អុសព្រៃលិចទឹកធ្វើអាជីវកម្ម ។
- ហាមការកាប់រានដីព្រៃលិចទឹក ។
- ហាមការធ្វើស្រែក្នុងបឹងត្រពាំង (ដីសាធារណៈរបស់រដ្ឋ) ។
- ហាមការបូមពង្រីងបឹង ត្រពាំង ឬ ស្រះ ដើម្បីចាប់ត្រី (ដីសាធារណៈរបស់រដ្ឋ) ។
- ហាមការដាំឈូកក្នុងបឹង ត្រពាំង ស្រះ (ដីសាធារណៈរបស់រដ្ឋ ) ។

ឃុំថ្មស,ថ្ងៃទី.....7.....ខែ.....5.....ឆ្នាំ 2010....

**មេឃុំ**

**អ៊ិត_ឃួន**

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកោះកុង

"ដើម្បីមេត្តាពិនិត្យ និង សំរេច"

បូទុមសាគរ,ថ្ងៃទី.....7....ខែ...5.....ឆ្នាំ 2010....

**អភិបាលនៃគណៈអភិបាលស្រុក**

**និង ប្រធានក្រុមការងារដីរដ្ឋ**

**ស្រុកបូទុមសាគរ**

**បានឃើញ និង ឯកភាព**

កោះកុង,ថ្ងៃទី..០៥.....ខែ..ឧសភា...ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ**

**ខេត្តកោះកុង**

**ប៊ុន លើត**

## ឧបសម្ព័ន្ធ ១
## ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានប្រជុំជន**

ដីលំនៅដ្ឋានប្រជុំជននៅក្នុងឃុំថ្មស គឺជាដីសំរាប់ការសាងសង់ផ្ទះដែលមានទំហំតូចៗ ពុំមានដីសំរាប់ធ្វើការដាំដំណាំឡើយ ។ ដីប្រភេទនេះភាគច្រើនជាដីតំបន់ពានិជ្ជកម្ម ដូចជាទីផ្សារលក់ដូរ ការដោះដូរទំនិញ ផ្ទះសំណាក់ ភោជនីដ្ឋាន... ។

- **ដីលំនៅដ្ឋានភូមិ**

ដីលំនៅដ្ឋានឃុំថ្មសភាគច្រើនស្ថិតនៅតាមមាត់សមុទ្រ និងនៅតាមដងផ្លូវលំក្រាល គ្រួសក្រហមជាដីខ្ពស់មិនងាយលិចទឹកជំនន់ និង ការជោរ រីនាច នៃទឹកសមុទ្រ ឃុំថ្មសប្រជាជន ភាគច្រើនរស់នៅតាមឆ្នេរសមុទ្រ បានដាំដំណាំរួមផ្សំដូចជា ម្ទេស ស្ពៃ ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ចេក ដូង ដំឡូង ស្វាយ ខ្នុរ ត្រកួន ... ។ល ។

- **ដីភូមិលាយស្រែ**

ដីភូមិលាយស្រែគឺជាដីភាគច្រើនជាដីភូមិដែលស្ថិតនៅដាច់ពីគ្នា ហើយនៅក្នុងរង្វង់ដីភូមិមានដីស្រែផ្នែកខាងលើនៃដីភូមិ ។ ចំពោះដីស្រែទំនាបមានដូចជានៅភូមិចំលងគោ ភូមិស្រែត្រាវ ភូមិចំការលើ ភូមិស្រែថ្មី ដីស្រែ ទាំងនោះភាគច្រើនមានទំហំ តូច រឺ ធំ ទៅតាមស្ថានភាពដីជាក់ស្តែង បន្ទាប់ពីធ្វើស្រែវស្សា ដីទាំងនេះភាគច្រើននៅទំនេរ និងដីមួយចំនួនតូចដាំដំណាំរួមផ្សំនៅរដូវប្រាំង ដូចជា ពោត សណ្តែក សណ្តែកគួរ ត្រប់ ត្រសក់ ស្ពៃ ត្រកួន ឪឡឹក ,,, ។ល ។



- **<u>ដីស្រែវស្សា ( ស្រូវស្ទូង)</u>**

ដីស្រែវស្សានៅឃុំថ្មសត្រូវបានប្រើប្រាស់ក្នុងការធ្វើស្រែបានតែមួយរដូវកាលប៉ុណ្ណោះ ដីទាំងនោះមិនមានប្រភព ទឹក ឬ អាងស្តុកទឹក ធ្វើស្រែពឹងផ្អែកទៅលើភ្លៀងទាំងស្រុង ពូជស្រូវដែលប្រើនៅទីនោះមានដូចជា : ពូជស្រូវស ស្រូវសូម៉ាលី ឡឹកវ៉ាយ ទិន្នផលបានចំនួន ០២ តោន ទៅ ០៣ តោន គិតជាមធ្យម។ ដីស្រែវស្សានៅក្នុងឃុំ សរុបមាន ៥៥៦,៩៧ ហិចតា និងស្រូវចំការ ៥៥,00 ហិចតាប៉ុណ្ណោះ។ ប៉ុន្តែបច្ចុប្បន្នការធ្វើស្រែនៅពុំទាន់អនុវត្តអោយបានអស់លទ្ធភាពដោយប្រជាកសិករភាគច្រើនខ្វះកំលាំងអូសទាញ និងដីមួយចំនួនទៀតត្រូវបានលក់ទៅអោយអ្នកដែលមិនប្រកបរធ្វើស្រែ និងដីស្រែមួយចំនួនទៀតពុំសូវមានជីវជាតិ ទុកទំនេរចោលដែលមិនទាន់បានធ្វើការស្តារ ឡើងវិញនៅឡើយ ។



- **<u>ចំការឈើហូបផ្លែ</u>**

ចំការឈើហូបផ្លែនៅឃុំថ្មសភាគច្រើនមាននៅលើដីទួល និងដីទំនាបក្បែរប្រភពទឹកដូចជាព្រែក រឹអូរ ហើយជាទូទៅប្រជាជនដាំដំណាំដែលមានរយះពេលវែង ដូចជា ធុរេន មង្ឃុត ដូង ចេក ដំឡូង ស្វាយ ទៀប ខ្នុរ មៀន ចន្ទីទឹកដោះគោ ... ។ល។ ចំការនៅលើដីទួលពិបាករកប្រភពទឹកមកស្រោចស្រពនៅរដូវប្រាំង ឯដីនៅទីទំនាបវិញ គឺស្រស់បំព្រងស្ទើរគ្រប់រដូវ ឯទិន្នផលក៏បានច្រើនជាងនៅលើដីទួលផងដែរ ។ ដីដែលផ្តល់អំណោយផលចំពោះដំណាំប្រភេទ ទាំងនេះ សព្វថ្ងៃប្រជាពលរដ្ឋបានដាំជាបន្តបន្ទាប់ជាច្រើនដើម្បីលើកស្ទួយជីវភាពគ្រួសារទៅថ្ងៃអនាគត ។




- **<u>ចំការព្រៃដាំ</u>**

ចំការព្រៃដាំនៅឃុំថ្មសមានដូចជា ពពួកខ្លឹមចន្ទ័គ្រឹស្នា អាកាស្យា កោងកាង កៅស៊ូដំណាំទាំងនេះមានអាយុកាលទទួលផលចាប់ពី ៣ ទៅ ៤ ឆ្នាំ និងផ្ទៃដីមានដូចខាងក្រោម :

- ខ្លឹមច័ន្ទគ្រឹស្នា : ៥២ ហិចតា
- អាកាស្យា : ១៥ ហិចតា
- កៅស៊ូ : ២,៧៦ ហិចតា

- **<u>ដីកសិកម្មពនេចរ</u>**

កាលពីដើមឡើយនៅក្នុងឃុំថ្មសការធ្វើស្រូវចំការពនេចរជាប្រពៃណីទៅហើយ គឺគេទំលាប់កាប់ព្រៃដាំស្រូវវិលជុំវ ាល់នៅកន្លែងធ្លាប់បានធ្វើកន្លងមក ។ បច្ចុប្បន្នច្បាប់បរិស្ថានបានហាមឃាត់រាល់កាប់រានទន្រ្ទានយកដីធ្វើ ចំការ ពនេចរនេះតទៅទៀត ហើយបច្ចុប្បន្នដីប្រភេទនេះមួយចំនួនបានដុះស្មៅប្រភេទស្បូវ និងព្រៃឈើតូចៗឡើងវិញ ។

-ដីចំការពនេចរមានទំហំ ៤៥.៩០៣ ហិចតា

- **<u>ចំការស្វាយចន្ទី</u>**

នៅក្នុងឃុំថ្មសអំឡុងឆ្នាំ ២០០៤-២០០៥ កាលនោះទីផ្សារគ្រាប់ស្វាយចន្ទីរមានតំលៃគួរសម ១គ.ក ស្មើ ២.៥០០៛ ទៅ៣.០០០៛ពេលនោះមានប្រជាពលរដ្ឋមួយចំនួនបាននាំគ្នាដាំលើផ្ទៃដីសរុប ១៧១.១៧៣ ហិចតា ។




| ល.រ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| 1 | Code :1100<br>ដីលំនៅដ្ឋានប្រជុំជន : |  |
| 2 | Code :1200<br>ដីលំនៅដ្ឋានភូមិ : ផ្ទះ-ទីសំណាប-ឈើហូបផ្លែ |  |
| 3 | Code : 2110 1300<br>ហេដ្ឋារចនាសម្ព័ន្ធ |  |

| | | |
|---|---|---|
| | | |
| 4 | Code : 3500 2110<br>ដីស្រែវស្សា : |  |
| 5 | Code : 4100 2113<br>វាលស្មៅ  ដីស្រែខ្សោះជីវជាតិ: |  |
| 6 | Code : 2200<br>ដីចំការដំណាំ: | <br> |
| 7 | Code : 2310<br>ចំការឈើហូបផ្លែ : |  |
| 8 | Code : 2311<br>ឈើហូបផ្លែ  ចំការដំណាំលើដីភូមិចាស<br>, |  |

| | | |
|---|---|---|
| 9 | Code :2321<br>ចំការកៅស៊ូ: |  |
| 10 | Code :2323<br>ចំការស្វាយចន្ទី: | |
| 11 | Code : 2400<br>កសិកម្មពនេចរ: | |
| 12 | Code :3110<br>ព្រៃស្រោង: | |
| 13 | Code :3210<br>ព្រៃរបោះ: | |
| 14 | Code :3220<br>ព្រៃរបោះស្តើងស្ងួត: | |
| 15 | Code :3300<br>ព្រៃចំរុះ: | |
| 16 | Code :3310<br>ព្រៃដុះតាមមាត់ទឹក: | |
| 17 | Code :3400<br>ព្រៃដុះឡើងវិញ: |  |
| 18 | Code :3500<br>ព្រៃលិចទឹក: | |
| 19 | Code :3510<br>ព្រៃលិចទឹកក្រាស់: | |
| 20 | Code :3600<br>ព្រៃកោងកាង: |  |

| | | |
|---|---|---|
| 21 | Code :3610<br>ព្រៃកោងកាងស្តើង: |  |
| 22 | Code :3800<br>ល្បាយដីព្រៃលាយដីកសិកម្ម: |  |
| 23 | Code :4100<br>វាលស្មៅ: | |
| 24 | Code :4110<br>ចំការបោះបង់ដុះស្មៅ: | |
| 25 | Code :4200<br>វាលស្មៅលិចទឹក: | |
| 26 | Code :4500<br>ព្រៃគម្ពោធ: | |
| 27 | Code :4510<br>ចំការបោះបង់ដុះព្រៃគម្ពោធ: | |
| 28 | Code :4600<br>ព្រៃគម្ពោធលាយដើមឈើធំមួយៗ: | |
| 29 | Code :5120<br>អាងស្តុកទឹក: | |
| 30 | Code :5130<br>ស្រះ: |  |

| | | |
|---|---|---|
| 31 | Code 5210<br>ព្រែក, ស្ទឹង, អូរ: |  |
| 32 | Code :5220<br>សមុទ្រ: | |
| 33 | Code :5300<br>វាលភក់: | |
| 34 | Code :6200<br>ខ្សាច់: | |
| 35 | Code :6300<br>ដីគ្មានរុក្ខជាតិដុះគ្របដណ្ដប់: | |
| 36 | Code :6420<br>ព្រៃកាប់ឆ្ការ: |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពការគ្រប់គ្រង និង កាន់កាប់ដីបច្ចុប្បន្ន (ផែនទី A-3 )

| ល,រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រងនិងកាន់កាប់ដី | | ក្រលាផ្ទៃ (ហិចតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត និង តួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ-ឯកជនរបស់ | |
| 1 | តំបន់ការពាររបស់ឧទ្យានជាតិបូទុមសាគរ | ដីសារធាណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | 23,714.60 |
| | ព្រៃលិចទឹក | ដីសារធាណៈរបស់រដ្ឋ | 1,470.3448 |
| | ព្រៃលិចទឹក( ក្រាស) | ដីសារធាណៈរបស់រដ្ឋ | 796.0783 |
| | ដីវាលស្មៅ | ដីសារធាណៈរបស់រដ្ឋ | 3,222.6052 |
| | ដីវាលស្មៅលិចទឹក | ដីសារធាណៈរបស់រដ្ឋ | 190.9353 |
| | បឹង ស្ទឹង អូរ | ដីសារធាណៈរបស់រដ្ឋ | 91.1138 |
| 2 | ដីសហគមន៏នេសាទ | ដីសារធាណៈរបស់រដ្ឋ | 1,250.00 |
| 3 | ដីក្រុមហ៊ុនអភិវឌ្ឍន៏ទីក្រុង ( Union Development GroupCo Ltd) | ដីសារធាណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | 23,712.60 |

# ឧបសម្ព័ន្ធ ៣

## បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា,មូលហេតុ,ដំណោះស្រាយ)

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| ខ្វះផ្លូវគមនាគមន៍ | -ភូមិស្រែត្រាវ<br>-ភូមិចំការលើ<br>-ភូមិចំលងគោ<br>-ភូមិស្រែថ្មី | -លំបាកក្នុងការធ្វើដំណើរ<br>-ឆ្ងាយពីផ្សារ<br>-សាលារៀននៅឆ្ងាយ<br>-មជ្ឈមណ្ឌលនៅឆ្ងាយ | -សាងសង់ផ្លូវគ្រួសក្រហម<br>-សង់ស្ពានបេតុង |
| ខ្វះស្បៀង | -ភូមិស្រែត្រាវ<br>-ភូមិចំការលើ<br>-ភូមិចំលងគោ<br>-ភូមិស្រែថ្មី | -ខ្វះដីធ្វើស្រែ<br>-ខ្វះឧបករណ៍កសិកម្ម<br>-ទិន្នផលស្រូវទាប<br>-គ្មានមុខរបរច្បាស់លាស់ | -ស្តារដីស្រែចាស់<br>-ទិញគោ ក្របី<br>-ទិញគោយន្តភ្ជួរស្រែ<br>-ផ្តល់ពូជស្រូវដែលមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម<br>-វិគ្គប្រព័ន្ធកសិកម្មចំរុះ<br>-ពង្រីកផ្ទៃដីកសិកម្ម |
| ទិន្នផលស្រូវទាប | -ភូមិស្រែត្រាវ<br>-ភូមិចំការលើ<br>-ភូមិចំលងគោ<br>-ភូមិស្រែថ្មី | -ដីខ្វះជីវជាតិ<br>-សត្វល្អិតបំផ្លាញ<br>-ខ្វះច្ចេកទេសកសិកម្ម<br>-ខ្វះថ្នាំសំលាប់សត្វល្អិត | -ផ្តល់ថ្នាំសំលាប់សត្វល្អិត<br>-ផ្តល់ធុងបាញ់ថ្នាំ<br>-ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសដល់សហគមន៍(កសិកម្ម) |
| គ្មានកសិដ្ឋានចិញ្ចឹមសត្វ | -ភូមិស្រែត្រាវ<br>-ភូមិចំការលើ<br>-ភូមិចំលងគោ<br>-ភូមិស្រែថ្មី | -ខ្វះទីតាំងដី<br>-ខ្វះទុន<br>-ខ្វះពូជសត្វ<br>-ខ្វះបច្ចេកទេសចិញ្ចឹសត្វ | -បង្កើតកសិដ្ឋានចិញ្ចឹមសត្វ<br>-ផ្តល់ពូជសត្វស្រុក<br>-ផ្តល់ពូជពពែ<br>-ផ្តល់ពូជត្រី<br>-ជីកស្រះចិញ្ចឹមត្រី តាមលក្ខណៈគ្រួសារ<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ |
| កសិផលគ្មានទីផ្សារ | ០៤ ភូមិ | -គ្មានទីផ្សារលក់ដូរ | - បង្កើតទីផ្សារ<br>- បង្កើតសេវាម៉ាស៊ីនកិនស្រូវ |

| | | | |
|---|---|---|---|
| ខ្វះបណ្ដាញអគ្គិសនី | ០៤ ភូមិ | - គ្មានអគ្គិសនីប្រើប្រាស់ | - ដំឡើងប្រព័ន្ធអគ្គិសនី<br>- ប្រព័ន្ធអគ្គិសនីប្រើពន្លឺព្រះអាទិត្យ |
| កុមារមិនបានចូលរៀន | ០៤ ភូមិ | - ខ្វះសាលារៀន<br>- ខ្វះគ្រូ<br>- គ្រួសារក្រីក្រ | - សាងសង់សាលារៀន<br>- ផ្ដល់គ្រូបង្រៀន<br>- បើកថ្នាក់មតេយ្យ<br>- បណ្ដុះបណ្ដាលគ្រូមតេយ្យ<br>- បង្កើតបណ្ណាល័យ<br>- សង់អគារទីចាត់ការ |
| ល្បែងស៊ីសង | ០៥ ភូមិ | - ខ្វះការបង្ក្រាប<br>- មិនគោរពច្បាប់<br>- ច្បាប់ធូរលុង<br>- អសីលធម៌ក្នុងសង្គម | - បង្កើតក្រុមបង្ក្រាបល្បែងស៊ីសង និងក្មេងទំនើង<br>- បង្កើតកម្មវិធីមិត្តអប់រំមិត្ត<br>- ផ្សព្វផ្សាយច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ<br>- ផ្សព្វផ្សាយច្បាប់រដ្ឋប្បវេណី និងព្រហ្មទ័ណ្ឌ<br>- ផ្សព្វផ្សាយការប្រឆាំងការលេងល្បែងស៊ីសង |
| ចិញ្ចឹមសត្វអនាធិបតេយ្យ | ០៥ ភូមិ | - ខ្វះការគ្រប់គ្រង<br>-លែងសត្វអោយស៊ីដំណាំ អ្នកដទៃគ្មានការទទួលខុសត្រូវ | - អប់រំស្ដីពីការចិញ្ចឹមសត្វដោយសុវត្ថិភាព<br>- ធ្វើរបងព័ទ្ធដំបន់ចិញ្ចឹមសត្វ |
| អាវុធជាតិផ្ទុះគ្រប់ប្រភេទ | ០៥ ភូមិ | - រកអាវុធមិនទាន់ផ្ទុះ<br>- នែកអាវុធប្រមាញ់សត្វ<br>- លួចលាក់ទុកអាវុធនិងគ្រឿង ផ្ទុះ | - ផ្សព្វផ្សាយស្ដីពីការប្រើប្រាស់អាវុធជាតិផ្ទុះ<br>- អប់រំការយល់ដឹងអំពីមីន និងគ្រាប់មិនទាន់ផ្ទុះ<br>- ដកអាវុធជាតិផ្ទុះគ្រប់ប្រភេទ |
| ដីខ្សោះជីវជាតិ | ០៥ ភូមិ | - គ្មានជីវជាតិ<br>-ខ្វះបច្ចេកទេស កែប្រែគុណភាពដី<br>- ខ្វះជីរ | - បណ្ដុះបណ្ដាលធ្វើជីកំប៉ុស្ដិ៍<br>- បណ្ដុះបណ្ដាលធ្វើជីរគ្រប់ប្រភេទ<br>- បង្កើនជំរកសត្វប្រចៀវយកអាចម៍ |
| បាត់បង់ព្រៃឈើ | ០៥ ភូមិ | - កាប់ ដុត ទន្ទ្រានយកដីធ្វើកម្មសិទ្ធិ | - ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>- ផ្សព្វផ្សាយជំរុញការដាំកូនឈើ |

| | | | |
|---|---|---|---|
| | | | - អប់រំចំណេះដឹងបរិស្ថាន និងច្បាប់បរិស្ថាន<br>- អប់រំស្តីពីផលប្រយោជន៍ព្រៃឈើ |
| អនក្ខរជនច្រើន | ០៥ ភូមិ | - ជីវភាពក្រីក្រ | - បើកថ្នាក់អក្ខរកម្ម<br>- វគ្គបំប៉នថ្នាក់អក្ខរកម្ម<br>- កម្មវិធីអប់រំក្រៅប្រព័ន្ធ |
| សុខភាពទ្រុឌទ្រោម | ០៥ ភូមិ | - ហូបមិនគ្រប់គ្រាន់<br>- ខ្វះថ្នាំព្យាបាល<br>- ខ្វះអនាម័យ<br>- ធ្វើការហួសកំលាំង<br>- ខ្វះសេវាសុខភាព | - សង់ប៉ុស្តិ៍សុខភាព<br>- សង់បង្គន់អនាម័យ<br>- អប់រំចំណេះដឹងអាហាររូបបត្ថម្ភ<br>- បណ្តុះបណ្តាលឆ្មបបូរាណ |
| ខ្វះទឹកស្អាត | ០៥ ភូមិ | - គ្មានអណ្តូងលូ<br>- គ្មានអណ្តូងស្នប់<br>- គ្មានស្រះទឹក | - ជីកអណ្តូងលូ<br>- ជីកអណ្តូងស្នប់<br>- ជីកស្រះទឹក |
| គ្មានភ្លេងប្រពៃណី | ០៥ ភូមិ | - ឧបករណ៍តន្ត្រី | - បង្កើតវង់ភ្លេងប្រពៃណី<br>- ផ្តល់ឧបករណ៍ភ្លេង<br>- បណ្តុះបណ្តាលតន្ត្រីបូរាណ |
| ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី | | - គ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់<br>- គ្មានលទ្ធភាពធ្វើប័ណ្ណ<br>- តំលៃធ្វើប័ណ្ណខ្ពស់ | - ផ្តល់ប័ណ្ណកម្មសិទ្ធិស្របច្បាប់<br>- ផ្សព្វផ្សាយចំណេះដឹងច្បាប់ភូមិបាល<br>- ផ្សព្វផ្សាយជំរុញការងារចុះបញ្ជីដីធ្លី<br>- កំណត់ដំបន់ប្រើប្រាស់ដីធ្លី<br>- កំណត់ដំបន់រដ្ឋបាលភូមិឃុំ<br>- រៀបចំផ្លាកលេខផ្ទះ<br>- រៀបចំសណ្តាប់ធ្នាប់ សំណង់លំនៅដ្ឋាន<br>- កសាងប៉ាណូផ្សព្វផ្សាយបរិស្ថាន<br>- បង្កើតថ្នាលបណ្តុះកូនឈើ<br>- អប់រំផ្សព្វផ្សាយតំបន់ព្រៃការពាររបស់ឧទ្យានជាតិ<br>- ដាក់ធុងសំរាមសាធារណៈ |

| | | | |
|---|---|---|---|
| ខ្វះថាមពលឧស្ម័ន | ០៥ ភូមិ | - ខ្វះបច្ចេកទេសផលិតឧស្ម័នធម្មជាតិ | - បណ្តុះបណ្តាលការធ្វើឡចង្ក្រានជីវៈឧស្ម័ន<br>- បច្ចេកទេសធ្វើឡចង្ក្រានសន្សំអុស |
| ប្រាក់ចំណូលថយចុះ | ០៥ ភូមិ | - គ្មានមុខជំនាញ<br>- គ្មានមុខរបរ<br>- គ្មានទុន | - បង្កើតសិប្បកម្មកែច្នៃ ផ្តៅ ឬស្សី<br>- វគ្គជំនាញច្នៃផ្តៅ ឬស្សី<br>- បង្រៀនមុខជំនាញ កាត់ដេរ អុតសក់ កាត់សក់ សំអាងការ |
| អំពើហឹង្សាក្នុងគ្រួសារ | ០៥ ភូមិ | - ជីវភាពក្រីក្រ<br>- អវិជ្ជា<br>- សេពគ្រឿងស្រវឹង<br>- រំលោភសិទ្ធិមនុស្ស<br>- ល្បែងស៊ីសង | - វគ្គផ្សព្វផ្សាយច្បាប់អប់រំហឹង្សាក្នុងគ្រួសារ<br>- ផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ<br>- ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស |
| សុខភាពផ្លូវភេទ | ០៥ ភូមិ | -ខ្វះការយល់ដឹងអំពីការថែទាំសុខភាព<br>- ខ្វះអនាម័យពេលសំរាលកូន<br>- កូនច្រើន | - ផ្សព្វផ្សាយអំពីជំងឺកាមរោគ និង ជំងឺអេដស៏<br>- ផ្សព្វផ្សាយអំពីសុខភាពបន្តពូជ<br>- ផ្សព្វផ្សាយពន្យាកំណើត<br>- បណ្តុះបណ្តាលឆ្មបភូមិ<br>- ផ្សព្វផ្សាយអំពីការប្រើស្រោមអនាម័យ<br>- ផ្សព្វផ្សាយអំពីបំណិនជីវិត |
| ស្ត្រី និង កុមាររងគ្រោះ | ០៥ ភូមិ | - ចាញ់បោកគេ<br>- រំលោភសេពសន្ថិវគ្គ<br>- អវិជ្ជា<br>- ក្រីក្រ<br>- កំព្រា<br>- ចំណាកស្រុក | - ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរស្ត្រី និង កុមារ<br>- ផ្តល់សេវាគាំទ្រដល់ជនរងគ្រោះ<br>- ផ្សព្វផ្សាយការប្រឆាំងការរំលោភផ្លូវភេទស្ត្រី និងកុមារ |

## ឧបសម្ព័ន្ធ ៤

ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និង ជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ ។

| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោដៅនៃការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ |
| មានផ្លូវលំក្រាលគ្រួសក្រហមមានផ្លូវលំដីស | CDP | -ប្រជាពលរដ្ឋប្រមាណ ៦០%-៧០% មិនទទួលបាននូវផ្លូវគមនាគមន៍ប្រើតាមរយៈការកសាងផ្លូវលំគ្រួសក្រហម និង លើកផ្លូវលំដីស ដើម្បីងាយស្រួល ក្នុងការធ្វើដំណើរ និង ចរាចរណ៍ដឹកទំនិញផ្សេងៗ | - ជំរុញការសាងសង់ផ្លូវលំក្រាលក្រួសក្រហម និង ផ្លូវដីស<br>- កាត់បន្ថយ ការចំណាយទៅលើមធ្យោបាយធ្វើដំណើរ | - សាងសង់ផ្លូវលំក្រាលក្រួសក្រហម<br>- សង់ស្ពានបេតុង<br>- លើកផ្លូវលំដីស |
| មានប័ណ្ណកម្មសិទ្ធិស្របច្បាប់ | CDP | -ពង្រឹកគណៈកម្មការសុរយោដី និង បន្តយន្តការ<br>-ការជីកអណ្តូងលូ ស្រះទឹកធម្មតា មានអាងស្តុកទឹកភ្លៀងផ្សេងៗទៀត សំរាប់ដោះស្រាយទំនាស់ដីធ្លី និង ទំនាស់ផ្សេងៗទៀត ដើម្បីធានាឱ្យការដោះស្រាយយុត្តិធមិពិសេសការកំណត់ព្រំប្រទល់រដ្ឋបាលភូមិឃុំនិងតំបន់ប្រើប្រាស់ដី ផ្សេងៗ រៀបចំសណ្តាប់ធ្នាប់សំណង់ស្នាក់នៅឱ្យ ទៅលប់បំបាត់ភាពអនាធិតេយ្យផ្សេងៗ | -ជំរុញការផ្តល់ប័ណ្ណសំគាល់សិទ្ធិលើដីធ្លី<br>-សាងសង់ពាង ឬអាងស្តុកទឹកស្របច្បាប់<br>-លើកកំពស់ការអនុវត្តន៏ច្បាប់ដោះស្រាយទំនាស់ដីធ្លី<br>-ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលអោយបានត្រឹមត្រូវ<br>-ជំរុញនិងលើកំពស់ការរៀបចំថែរក្សាសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន | -ផ្តល់ប័ណ្ណកម្មសិទ្ធស្របច្បាប់<br>-ផ្សព្វផ្សាយចំណេះដឹងច្បាប់ភូមិបាល<br>-អាងស្តុកទឹក<br>-ផ្សព្វផ្សាយជំរុញការចុះបញ្ជីដីធ្លី<br>-កំណត់ព្រំប្រទល់រដ្ឋបាលភូមិឃុំ<br>-រៀបចំសណ្តាប់ធ្នាប់សំណង់លំនៅដ្ឋាន |

| | | | | |
|---|---|---|---|---|
| មានទីតាំងចិញ្ចឹមសត្វ | CDP | -បង្កើតអោយមានទីតាំងកសិដ្ឋានចិញ្ចឹមសត្វទទួលបានពូជសត្វល្អៗឆាប់ផ្តល់ផលជាអតិបរិមាលើកកំពស់ និង បង្កើនចំណេះដឹង ក្នុងការចិញ្ចឹមត្រីតាមរយៈការជីកស្រះចិញ្ចឹមតាមលក្ខណៈគ្រួសារ | -ជំរុញឱ្យមានកសិដ្ឋានចិញ្ចឹមសត្វ<br>-ជំរុញជីកស្រះចិញ្ចឹមត្រី | -បង្កើតកសិដ្ឋានចិញ្ចឹមសត្វស្រុក<br>-ជីកស្រះចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ |
| មានទីផ្សារ | | បង្កើតទីផ្សារលក់ផលិតផល | ជំរុញឱ្យមានទីផ្សារ | បង្កើតទីផ្សារ |
| មានសាលារៀន | | -កាត់បន្ថយចំងាយផ្លូវដែលកុមារធ្វើដំណើរពីផ្ទះមកកាន់សាលារៀននៅតាមភូមិដាច់ស្រយាល | -ជំរុញការសាងសង់បង្កើតសាលារៀនអនុវិទ្យាល័យ និង វិទ្យាល័យ | -សាងសង់សាលា រៀន |
| -មានបង្គន់អនាម័យ<br>-មានប៉ុស្តិ៍សុខភាព | | -ប៉ុស្តិ៍សុខភាព ការផ្តល់ថ្នាំព្យាបាលនិងចំណេះដឹងអាហារូបត្ថម្ភ មានបង្គន់អនាម័យ<br>-កែលំអសេវាកម្ម | -លើកកំពស់សេវាផ្តល់ថ្នាំព្យាបាល<br>-ជំរុញឱ្យមានចំណេះដឹងផ្នែកអាហារូបត្ថម្ភ | -អប់រំចំណេះដឹងអាហារូបត្ថម្ភ<br>-បណ្តុះបណ្តាលឆ្មបបុរាណ |
| -មានអណ្តូង លូ<br>- មានអណ្តូងដៃ<br>- មានស្រះទឹក<br>-មានទឹកប្រើប្រាស់ | | -ធ្វើអោយប្រសើរឡើង និង បង្កើតលទ្ធភាពប្រកបដោយចិរភាពក្នុងការទទួលបាន និង ប្រើប្រាស់ទឹកស្អាតតាមរយៈការជីកអណ្តូងលូមានស្រះទឹកធម្មតា មានអាងស្តុកទឹកភ្លៀង | -បង្កើតការជីកអណ្តូង លូ ស្នប់<br>-ជំរុញការជីស្រះទឹកសាសង់ពាង ឬ អាងស្តុកទឹក | ជីកអណ្តូង លូ<br>-ជីក អណ្តូងស្នប់<br>-ជីកស្រះធម្មតា<br>-ផ្តល់មធ្យោបាយចំរោះទឹកស្អាត<br>-អាងស្តុកទឹក |

## ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬ សកម្មភាព សំខាន់របស់ឃុំក្នុង រយៈ ១៥ ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | |
|---|---|---|---|---|---|---|
| | | ចំនួន | ឯកតា | ៥ឆ្នាំទី១ | ៥ឆ្នាំទី២ | ៥ឆ្នាំទី៣ |
| ២.៦.១ | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | |
| | ២.៦.១.១ | | | | | |
| | ១.១ ផ្លូវថ្នល់ | | | | | |
| | ១.១.១ ផ្លូវក្រាលបេតុង | 59.00 | ម៉ែត្រ | 59.00 | 00 | 00 |
| | ១.១.២ ផ្លូវក្រាលគ្រួសក្រហម និង ជួសជុល | 49,140.00 | ម៉ែត្រ | 3,204.00 | 10,411.00 | 35,525.00 |
| | ១.១.៣ ប្រវែងផ្លូវក្រាលដីស | 16,253.00 | ម៉ែត្រ | 16,253.00 | 00 | 00 |
| | ១.១.៤ ផ្លូវរទេះ ថ្មើរជើង | 74,300 | ម៉ែត្រ | 74,300 | 00 | 00 |
| | ១.២ ធ្វើទំនប់ការពារទឹកប្រៃ | 3,501 | ម៉ែត្រ | 2,000 | 1,501 | 00 |
| | ១.២.១ ប្រឡាយមេ | 7,759 | ម៉ែត្រ | 2,000 | 3,500 | 2,259 |
| | ១.២.១ ប្រឡាយរង | 2,122 | ម៉ែត្រ | 0.00 | 2.122 | 00 |
| | ១.៣ ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត | | | | | |
| | ១.៣.១ ចំនួនស្ពានថ្មបេតុង | 07 | កន្លែង | 04 | 03 | 00 |
| | ១.៣.២ ចំនួនស្ពានឈើ | 00 | | 00 | 00 | 00 |
| | ១.៣.៣ ចំនួនទ្វារទឹក | 02 | | 00 | 02 | 00 |
| | ១.៣.៤ ចំនួនលូកាត់ផ្លូវ | 07 | | 07 | 00 | 00 |

| | | | | | | |
|---|---|---|---|---|---|---|
| | ២,៦,១,២ ហេដ្ឋារចនាសម្ព័នសង្គម និង សេវាកម្មផ្សេងទៀត | 00 | | 00 | 00 | 00 |
| | ២,៦,១,២,១ ការសិក្សាអប់រំ | | | | | |
| | ២,៦,១,២,២ សាលាមតេ្តយ | 01 | 05បន្ទប់ | 01 | 00 | 00 |
| | ២,៦,១,២,៣ សាលាបឋមសិក្សា | 06 | 31បន្ទប់ | 02 | 02 | 02 |
| | ២,៦,១,២,៤ សាលាអនុវិទ្យាល័យ | 03 | 16បន្ទប់ | 01 | 01 | 01 |
| | ២,៦,១,២,៥ សាលាវិទ្យាល័យ | 04 | 20បន្ទប់ | 02 | 00 | 02 |
| | ២,៦,១,៣, សុខភាព និង អនាម័យ | | | | | |
| | ២,៦,១,៣,១ មណ្ឌលសុខភាព | 00 | បន្ទប់ | 00 | 00 | 00 |
| | ២,៦,១,៣,២ ប៉ុស្តិ៍សុខភាព | 04 | 16បន្ទប់ | 02 | 01 | 01 |
| | ២,៦,១,៣,៣ ស្រះទឹកស្អាត | 10 | កន្លែង | 05 | 05 | 00 |
| | ២,៦,១,៣,៤ អណ្តូងទឹកស្អាត | 14 | គ្រប់ភូមិ | 14 | 00 | 00 |
| | ២,៦,១,៣,៥ កន្លែងចាក់សំរាម | 05 | កន្លែង | 05 | 00 | 00 |
| | ២,៦,១,៤,១ ប៉ុស្តិ៍នគរបាល | 01 | កន្លែង | 01 | 00 | 00 |
| | ២,៦,១,៤,២ ទីតាំងផ្សារ | 01 | កន្លែង | 01 | 00 | 00 |
| | ២,៦,១,៥,១ កន្លែងគោរពបូជា | 00 | | 00 | 00 | 00 |
| | ២,៦,១,៥,២ វត្តអារាម | 01 | កន្លែង | 00 | 00 | 01 |
| | ២,៦,១,៥,៣ សាលាឆទាន | 01 | កន្លែង | 01 | 00 | 00 |
| ២,៦,២ | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | **២,៦,២,១ គំរោងផ្នែកប្រើប្រាស់ដីធ្លីតាម វិស័យធំៗ** | | | | | |
| | ២,៦,២,១,១ ដីសម្បទានសង្គមកិច្ច | 00 | | 00 | 00 | 00 |
| | ២,៦,២,១,២ ដីកន្លែងការពារឧទ្យានជាតិ | 00 | | 00 | 00 | 00 |
| | **២,៦,២,២ គំរោងប្រើប្រាស់ដីលក្ខណះ សហគមន៍** | | | | | |
| | ២,៦,២,២,១ ដីភូមិ | 111.09 | ហ ត | 111.09 | 00 | 00 |
| | ២,៦,២,២,២ ដីវាលកប់ខ្មោច | 5 | ហ.ត | 5 | 00 | 00 |
| | ២,៦,២,២,៣ ដីស្រោចស្រព | 00 | | 00 | 00 | 00 |
| | ២,៦,២,២,៤ ចំការដាំណាំហូបផ្លែ | 00 | | 00 | 00 | 00 |
| | ២,៦,២,២,៦ ដីសហគមន៏ព្រៃឈើ | 1,357 | ហ.ត | 1,357 | 00 | 00 |
| | ២,៦,២,២,៧ តំបន់អភិរក្សធនធានជលផល | 904 | ហ.ត | 904 | 00 | 00 |
| | ២,៦,២,២,៨ ដីស្រែវស្សា | 673 | ហ.ត | 673 | 00 | 00 |
| | ២,៦,២,២,៩ ដាំព្រៃកោងកាងឡើងវិញ | 495 | ហ.ត | 495 | 00 | 00 |
| | **២,៦,២,៣, គំរោផ្នែកបង្កើនជំនាញ និង មុខរបរ** | | | | | |
| | **២,៦,២,៣,១ វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែ** | 4វគ្គ | 4ភូមិ | 4វគ្គ | 00 | 00 |
| | ២,៦,២,៣,២ **វគ្គបណ្តុះបណ្តាលអំពីការប្រើដី** | | | | | |
| | **២,៦,៣,៣ វគ្គបណ្តុះបណ្តាលអំពីការប្រែគុណភាពដី** | 00 | | 00 | 00 | 00 |
| | **២,៦,៣,៣,៤ វគ្គបណ្តុះបណ្តាលអំពីកែច្នៃផ្តៅ ឬស្សី** | 07 | វគ្គ | 07 | 00 | 00 |
| | **២,៦,២,៣,២ផ្សព្វផ្សាយច្បាប់ភូមិបាល,រដ្ឋបាលព្រៃឈើ** | 05 វគ្គ | គ្រប់ភូមិ | ៥វគ្គ | 00 | 00 |